**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ
# កិច្ចប្រជុំលើកទី១របស់ក្រុមការងាររេដ+កម្ពុជា

ឆ្នាំពីរពាន់ដប់បី ខែកញ្ញា ថ្ងៃទីដប់មួយ វេលាម៉ោងពីរ និងសាមសិបនាទី នៅសណ្ឋាគារសូហ្វីតែលភូគីត្រាភ្នំពេញ មានបើកកិច្ចប្រជុំលើកទី១ក្រុមការងាររេដ+កម្ពុជា ក្រោមអធិបតីភាពឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ និងជាប្រធានក្រុមការងាររេដ+កម្ពុជា។ កិច្ចប្រជុំនេះបានរៀបចំឡើងដោយលេខាធិការដ្ឋានរេដ+កម្ពុជា។ អ្នកចូលរួមសរុបមានចំនួន ៣២នាក់ ដែលរួមមាន៖ សមាជិកក្រុមការងាររេដ+កម្ពុជា ៥នាក់ តំណាងសមាជិកក្រុមការងាររេដ+កម្ពុជា ៣នាក់ អ្នកសង្កេតការណ៍ ១០នាក់ និងបុគ្គលិកលេខាធិការដ្ឋានរេដ+កម្ពុជា ១៤នាក់។ (ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ២៖ បញ្ជីរាយនាមអ្នកចូលរួម)

## ១- មតិចាប់ផ្តើមបើកអង្គប្រជុំ

ឯកឧត្តម **ជា សំអាង** ជាប្រធានអង្គប្រជុំ បានថ្លែងបញ្ជាក់ថា ក្រុមការងាររេដ+កម្ពុជា មានតួនាទីសំខាន់ ក្នុងការរួមចំណែកធ្វើឲ្យប្រសើឡើង នូវជីវភាពរស់នៅប្រជាជននៅជនបទ តាមរយៈនៃការជួយរៀបចំយុទ្ធសាស្ត្រ និងក្របខ័ណ្ឌការងាររេដ+ ដើម្បីគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តរភាព ដែលជួយដល់ការកាត់បន្ថយការបម្រែបម្រួលអាកាសធាតុ ព្រមពេលជាមួយគ្នានេះ និងបានចំណូលជាតិពីហិរញ្ញប្បទានកាបូន សម្រាប់ចែករម្លែកដល់អ្នកចូលរួមក្នុងការងារគ្រប់គ្រងព្រៃឈើផងដែរ។ ឯកឧត្តម ក៏បានបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ក្រសួងពាក់ព័ន្ធ ក្នុងដំណើរការត្រៀមលក្ខណៈសម្រាប់រេដ+នៅកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ដែលមានតួនាទីសំខាន់ក្នុងការងារចែករម្លែកប្រយោជន៍ដល់អ្នកពាក់ព័ន្ធ។

មានគម្រោង និងដៃគូជាច្រើនកំពុងគាំទ្រដំណើរការត្រៀមលក្ខណៈសម្រាប់រេដ+នៅកម្ពុជា ដូចជា៖ UN-REDD, CAM-REDD, JICA, FCPF, TCP-NFI, LEAF និងគម្រោងដទៃទៀត ។ បច្ចុប្បន្នយើងកំពុងស្ថិតនៅដំណាក់កាលទី១ គឺការរៀបចំយុទ្ធសាស្ត្រ និងក្របខ័ណ្ឌការងារ សម្រាប់ការអនុវត្តរេដ+។ នៅដំណាក់កាលទី២ ជាការចាប់ផ្តើមអនុវត្តនៅលើទីវាលសាកល្បង ដែលត្រូវការធនធានច្រើនជាងនេះសម្រាប់គាំទ្រ។ នៅពេលក្របខ័ណ្ឌការងារ និងឯកសារប្រព័ន្ធការងារបានបង្កើតគ្រប់ជ្រុងជ្រោយហើយ គឺជាដំណាក់កាលទី៣ ដែលអនុវត្តពេញលេញ និងមានការលក់កាបូនព្រៃឈើ។

ពេលនេះនឹងមាននិរន្តរភាពចំណូល សម្រាប់ទ្រទ្រង់ការគ្រប់គ្រងព្រៃឈើ និងសហគមន៍ដែលបានរួមចំណែកក្នុងវិស័យព្រៃឈើ បន្ថែមលើប្រភពចំណូលដែលមានស្រាប់របស់គាត់។

## ២- ការណែនាំខ្លួនរបស់អ្នកចូលរួម

កិច្ចប្រជុំបានអនុញ្ញាតឲ្យអ្នកចូលរួមទាំងអស់ធ្វើការណែនាំខ្លួន ដោយបញ្ជាក់ពីឈ្មោះ តួនាទីភារកិច្ច និងស្ថាប័នការងាររបស់ខ្លួន។

## ៣- ការធ្វើបទបង្ហាញ និងពិភាក្សា

❖ *យន្តការរេដ+ជាសកល*

ការធ្វើបទបង្ហាញរបស់ លោក **ភីតធឺ អ៊ីវីស៊ិន** អ្នកជំនាញបច្ចេកទេស បានលើកឡើងពីបញ្ហាសំខាន់ៗដែលពាក់ព័ន្ធ នឹងរេដ+នៅលើពិភពលោក រួមមាន៖ ការកើនឡើងនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ ការបាត់បង់ព្រៃឈើ ជារៀងរាល់ឆ្នាំ ក្របខ័ណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ កិច្ចព្រមព្រៀងកាន់គុន (Cancun Agreement) ស្ថានភាពបច្ចុប្បន្ននៃដំណើរការរេដ+ ការចរចារស្តីពីរេដ+កំពុងបន្តនៅលើពិភពលោក។ (ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ៥៖ បទបង្ហាញ)

❖ *វឌ្ឍនភាពរេដ+នៅកម្ពុជា និងសកម្មភាពជាអាទិភាព*

បទបង្ហាញបានធ្វើឡើងដោយ លោក ឃុន វឌ្ឍនា ប្រធានលេខាធិការដ្ឋានរេដ+ បានផ្តោតសំខាន់លើ៖

(១)ការចូលរួមរបស់កម្ពុជាទៅក្នុងដំណើរការរេដ+ ដែលបង្ហាញពីដំណាក់កាលជាបន្តបន្ទាប់របស់កម្ពុជាចូលជាសមាជិក FCPF និង UN-REDD ការបង្កើតផែនទីបង្ហាញផ្លូវ ការទទួលបានកម្មវិធី UN-REDD គម្រោង CAM-REDD និងគម្រោងដទៃទៀត។

(២)កម្មវិធីនិងគម្រោងនានាដែលកំពុងគាំទ្រដំណើរការត្រៀមលក្ខណៈសម្រាប់ការអនុវត្តរេដ+ នៅកម្ពុជា ដែលកម្មវិធីនិងគម្រោងទាំងនេះ ផ្តោតសំខាន់លើការបង្កើតឲ្យមានស្ថាប័ន គោលនយោបាយ ក្របខ័ណ្ឌការងារសំខាន់ៗ និងការកសាងសមត្ថភាព។

(៣)វឌ្ឍនភាពរេដ+នៅកម្ពុជានាពេលបច្ចុប្បន្ន ដែលបង្ហាញពី៖ ការបង្កើតក្រុមការងាររេដ+កម្ពុជាជាផ្លូវការ ការរៀបចំឲ្យមានលេខាធិការដ្ឋាន ការបង្កើតគេហទំព័ររេដ+កម្ពុជា ការផលិតឯកសារព័ត៌មានផ្សព្វផ្សាយអប់រំ ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងរេដ+ ការបង្កើតក្រុមប្រឹក្សាយោបល់ ការគាំទ្រគម្រោងសាកល្បងរេដ+នៅឧត្តរមានជ័យ សីម៉ា និងគូលេនព្រហ្មទេព និងការគាំទ្រថវិកាបច្ចេកទេសដល់ទីភ្នាក់ងារអនុវត្តរួមមានរដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្ស

ធម្មជាតិ និងរដ្ឋបាលជលផល ដើម្បីកសាងសមត្ថភាព និងបង្កើតជម្រើសផ្សេងៗសម្រាប់អនុវត្តរេដ+ និងការបង្កើតផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារ និងអភិរក្សធម្មជាតិ ។ (ព័ត៌មានបន្ថែមសូមអាន ឧបសម្ព័ន្ធ៥៖ បទបង្ហាញ)

❖ លក្ខខ័ណ្ឌការងារក្រុមការងារបច្ចេកទេសរេដ+កម្ពុជា

លោក **លន់ គឹមហ៊ី** អ្នកសម្របសម្រួលកម្មវិធី បានធ្វើបទបង្ហាញ លក្ខខ័ណ្ឌការងារទូទៅ របស់ក្រុមការងារបច្ចេកទេស រេដ+កម្ពុជាទាំងបួនក្រុម និងមានការពន្យល់បន្ថែមដោយ លោក **ឈុន ឌីលុច** លោក **ឡុង រតនកុមារ** និងលោកស្រី **សារ សុភ៉ា** អំពីគោលបំណង និងកិច្ចការងារបច្ចេកទេសរបស់ក្រុមទាំងបួនជូនក្រុមការងាររេដ+កម្ពុជា។ គោលបំណង គឺស្នើសុំក្រុមការងាររេដ+កម្ពុជា ពិភាក្សា ផ្តល់យោបល់កែលំអ និងអនុម័តលើលក្ខខ័ណ្ឌការងាររបស់ក្រុមការងារបច្ចេកទេសទាំង៤។ (ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ៥៖ បទបង្ហាញ)

**ការពិភាក្សា**

លោកស្រី **ពៅ វរលក្សណ៍** បានលើកសំណួរ និងពិភាក្សា លើសមាសភាពសមាជិករបស់ក្រុមការងារបច្ចេកទេសទាំងបួន ជាពិសេសការបញ្ចូលសមាជិកមកពីអគ្គនាយកដ្ឋានថាមពលនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ លោកស្រីសុំឲ្យមាន ការពន្យល់ពាក្យបច្ចេកទេស នៅតាមរឹមផ្នែកខាងក្រោមនៃឯកសារ ដើម្បីងាយយល់ពាក្យបច្ចេកទេសទាំងនេះ។ លោកស្រីក៏បានស្នើសុំឲ្យលេខាធិការដ្ឋាន ផ្តល់ជូនគោលគំនិតសម្រាប់ការអនុវត្តគម្រោង ដែលលេខាធិការដ្ឋាន បានផ្តល់ថវិកាជូន រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងរដ្ឋបាលជលផល។

ឯកឧត្តម **ជាម ប៉េអា** មានការព្រួយបារម្មណ៍ពីការចូលរួម និងការឧបត្ថម្ភគាំទ្រ ក៏ដូចជានិរន្តរភាពការងាររបស់ក្រុមបច្ចេកទេស ដោយសារមានសមាជិកច្រើន។ ឯកឧត្តមស្នើសុំថាលេខាធិការដ្ឋានគួរបំពេញការងារបច្ចេកទេស និងដាក់ឯកសារជូនក្រុមការងាររេដ+កម្ពុជា ដើម្បីពិនិត្យ និងអនុម័ត ដោយមិនចាំបាច់បង្កើតក្រុមការងារបច្ចេកទេស។ ឯកឧត្តម ក៏បានផ្តល់អនុសាសន៍ថា តួនាទីរបស់ក្រុមបច្ចេកទេសគួរបញ្ចូល ការសិក្សាពីលទ្ធភាព រវាងអ្នកប្រើប្រាស់ និងអ្នកការពារ ដើម្បីជានាឲ្យការចែករម្លែកផលប្រយោជន៍មានសមធម៌។ ផ្ទុយពីនេះឯកឧត្តមសុំឲ្យដកចេញចំណុចប្រឹក្សាយោបល់ជាមួយអ្នកឯកទេសប្រឆាំង អំពើពុករលួយ ចេញពីការទទួលខុសត្រូវរបស់ក្រុមបច្ចេកទេស។

លោក **គឹម ណុង** សុំឲ្យមានការពិចារណា ថារេដ+ត្រូវអនុវត្ត និងធ្វើសមាហរណកម្ម ដោយរបៀបណាជាមួយដំណើរការដែលមានស្រាប់ ជាពិសេសសហគមន៍ព្រៃឈើ សហគមន៍តំបន់

ការពារធម្មជាតិ ដែលជាដំណើរការដ៏មានប្រសិទ្ធភាព និងមាននិរន្តរភាព ក្នុងការបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងព្រៃឈើ។

លោក **ប៊ុន រ៉ាស៊ី** ស្នើសុំឲ្យមានការយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយ ឲ្យបានល្អមុនពេលអនុវត្តរេដ+នៅសហគមន៍មូលដ្ឋាន និងគួរបន្តឲ្យមានការចូលរួមពីតំណាងជនជាតិដើមភាគតិចដែលបានជ្រើសរើសកន្លងមកនៅខេត្តទាំង១៥។

លោក **ទាង ឆាយហៀង** ស្នើសុំឲ្យមានការពន្យល់ ពីមូលហេតុនៃការបញ្ចូលក្រសួងអភិវឌ្ឍន៍ជនបទជាសមាជិកក្រុមការងារបច្ចេកទេសប្រព័ន្ធការពារសុវត្ថិភាព។ ក្រោយការពន្យល់ ជាបន្ថែម លោកក៏បានស្នើសុំឲ្យក្រសួងអភិវឌ្ឍន៍ជនបទចូលជាសមាជិកក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍។

**ការសម្រេច**

- លេខាធិការដ្ឋានរាយការណ៍ អំពីគោលគំនិតសម្រាប់ការអនុវត្តគម្រោងជូនក្រុមការងាររេដ+។
- ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដ+៖ បន្ថែមសមាជិកមកពីអគ្គនាយកដ្ឋានថាមពល ១នាក់។ បន្ថែមសមាជិកមកពីរដ្ឋបាលព្រៃឈើ ១នាក់ (សរុប២នាក់)។ កាត់ចេញសមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែអាចអញ្ជើញមកចូលរួមតាមការចាំបាច់។
- ក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍រេដ+៖ បន្ថែមសមាជិកមកពីអគ្គនាយកដ្ឋានថាមពល ១នាក់។ បន្ថែមសមាជិកមកពីក្រសួងអភិវឌ្ឍន៍ជនបទ ១នាក់ ។ កាត់ចេញសមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាល ដូចខាងលើ។ តួនាទី ត្រូវបន្ថែមការសិក្សាពីលទ្ធភាពនៃអ្នកប្រើប្រាស់ និងអ្នកការពារ ដើម្បីធានាការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌។
- ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូរេដ+៖ បន្ថែមសមាជិកឲ្យបានគ្រប់ស្ថាប័ន ដូចសមាជិកក្រុមការងាររេដ+ដើម្បីសិក្សារួមគ្នា។ កាត់ចេញសមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាលដូចខាងលើ។
- ក្រុមការងារបច្ចេកទេស MRV/REL៖ បន្ថែមសមាជិកមកពីអគ្គនាយកដ្ឋានថាមពល ១នាក់។ កាត់ចេញសមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាលដូចខាងលើ។
- សុំឲ្យធ្វើការពិនិត្យទៅលើការបកប្រែ និងកែសម្រួលល័ក្ខខ័ណ្ឌការងារនេះឡើងវិញ និងបន្ទាប់ពីបានកែសម្រួលការបកប្រែ និងរួមបញ្ចូលមតិយោបល់ដែលបានសម្រេច ក្នុងកិច្ចប្រជុំ ត្រូវផ្ញើជូនលោកបណ្ឌិត កែវ អូម៉ាលីស្ស ដើម្បីជួយពិនិត្យកែសម្រួលបន្ថែម។

➢ សុំឲ្យមានការធ្វើបទបង្ហាញណែនាំអំពីក្រុមការងារបច្ចេកទេស MRV/REL ឲ្យបានស៊ីជម្រៅ ដើម្បីឲ្យក្រុមការងាររេដ+យល់ដឹងបន្ថែមពីលក្ខណៈបច្ចេកទេសរបស់ក្រុមនេះ និងងាយស្រួលក្នុងការដឹកនាំ។

❖ ***សំណើឲ្យកម្មវិធី UN-REDD ដឹកនាំបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងរេដ+កម្ពុជា*** (REDD+ Cambodia Communication Strategy)

បទបង្ហាញធ្វើឡើងដោយកញ្ញា ជី ហៀង មន្ត្រីទំនាក់ទំនង មានគោលបំណង ស្នើសុំក្រុមការងាររេដ+កម្ពុជា អនុញ្ញាតិឲ្យលេខាធិការដ្ឋាន ដឹកនាំបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងរេដ+សម្រាប់កម្ពុជា ដែលនឹងចាប់ផ្តើមនៅដើមត្រីមាសទី៤ ឆ្នាំ២០១៣នេះ។ បទបង្ហាញបញ្ជាក់ថា គម្រោងរេដ+ទាំងអស់នៅកម្ពុជា មានយុទ្ធសាស្ត្រទំនាក់ទំនងរេដ+ផ្សេងៗគ្នា ដូច្នេះវិធីសាស្ត្រក្នុងការបញ្ជូនព័ត៌មាន ក៏ដូចជាការបញ្ចេញសារនានា ពាក់ព័ន្ធនឹងការត្រៀមលក្ខណៈសម្រាប់រេដ+ អាចមានអត្ថន័យមិនស្របគ្នា ពិបាកយល់ និងមានការភ័ន្តច្រឡំ។ បញ្ហានេះដោយសារយើងពុំទាន់មានយុទ្ធសាស្ត្រទំនាក់ទំនងត្រឹមត្រូវ និងឯកភាពគ្នា។ លេខាធិការដ្ឋាន បានផ្តួចផ្តើមពិភាក្សាជាមួយដៃគូពាក់ព័ន្ធ និងបានចម្លើយថាគួរបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងរេដ+មួយសម្រាប់កម្ពុជា។ អនុវត្តតាមគំនិតនេះ លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំជាមួយដៃគូពាក់ព័ន្ធ និងបានកំណត់តម្រូវការ ជាមួយនិងការប្រមូលឯកសារផ្សព្វផ្សាយទំនាក់ទំនងដែលមានស្រាប់ និងបានរៀបចំផែនការបោះពុម្ព ផ្សព្វផ្សាយទៅលើផ្នែកដែលខ្វះខាត។ ជាមួយគ្នានេះ លេខាធិការដ្ឋាន ក៏បានបង្កើតនូវព្រឹត្តិបត្រព័ត៌មានលេខទី១ ខិត្តប័ណ្ណអំពីរេដ+កម្ពុជា និងវីដេអូឃ្លីបអំពីរេដ+ផងដែរ។ (ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ៥៖ បទបង្ហាញ)

**ការសម្រេច**

➢ អនុញ្ញាតឲ្យលេខាធិការដ្ឋាន សម្របសម្រួលបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងរេដ+កម្ពុជា។ បន្ទាប់ពីការបង្កើតបានសេចក្តីព្រាង លេខាធិការដ្ឋាន ត្រូវធ្វើបទបង្ហាញជូនក្រុមការងាររេដ+កម្ពុជា ដើម្បីពិនិត្យ និងអនុម័ត។

❖ ***ទស្សនៈកិច្ចសិក្សានៅវៀតណាម***

បទបង្ហាញធ្វើឡើងដោយលោក តុល សុខជា មន្ត្រីផ្នែកបណ្តុះបណ្តាល មានគោលបំណង ស្នើសុំក្រុមការងាររេដ+កម្ពុជា អនុម័ត និងចូលរួមទស្សនកិច្ចសិក្សា ដើម្បីស្វែងយល់ពីបទពិសោធន៍ពាក់ព័ន្ធនឹងការសម្របសម្រួលគាំទ្រលើដំណើរការត្រៀមលក្ខណៈសម្រាប់រេដ+នៅប្រទេសវៀតណាម។ ទស្សនកិច្ចសិក្សា មានរយៈពេល ៥ថ្ងៃ (០៧ ដល់ ១១ ខែតុលា ឆ្នាំ២០១៣) ដែលសហការរៀបចំដោយ រដ្ឋបាលព្រៃឈើ នៃប្រទេសវៀតណាម (VNFOREST) និង RECOFTC វៀតណាម។ (ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ៥៖ បទបង្ហាញ)

**ការសម្រេច**

- ក្រុមការងារអនុម័ត និងចូលរួមទស្សនកិច្ចសិក្សានៅប្រទេសវៀតណាមរយៈពេល ៥ថ្ងៃ ។
- ក្រុមការងាររេដ+សំណូមពរ ឲ្យដាក់បញ្ចូលបន្ថែមនូវរបៀបវារៈ ការកសាងសមត្ថភាព។

❖ ***តម្រូវការចំណាយប្រចាំខែ សម្រាប់ការងារទំនាក់ទំនង ការរៀបចំឯកសារប្រជុំ និងការធ្វើដំណើរ របស់ក្រុមការងាររេដ+កម្ពុជា***

*លោកស្រី ប៉ាន់ ធីតា មន្ត្រីហិរញ្ញវត្ថុ និងលទ្ធកម្ម ស្នើសុំឲ្យពិចារណា និងអនុម័ត ការឧបត្ថម្ភចំនួន ៥០ដុល្លាអាមេរិក ក្នុង១ខែ សម្រាប់ចំណាយទំនាក់ទំនង ការរៀបចំឯកសារប្រជុំ និងការធ្វើដំណើរ របស់ក្រុមការងាររេដ+កម្ពុជា។ ជាបន្ថែម សំណូមពរសុំទិញកុំព្យូទ័រ សម្រាប់បំពេញការងាររបស់ក្រុមការងាររេដ+កម្ពុជា ។*

**ការសម្រេច**

- ក្រុមការងាររេដ+ឯកភាពឧបត្ថម្ភចំណាយចំនួន ៥០ដុល្លាអាមេរិក ក្នុង១ខែ ។

❖ ***លទ្ធផលជ្រើសរើសតំណាងក្រុមប្រឹក្សាយោបល់***

*ក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដ+កម្ពុជាចំនួន១៨នាក់ ត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៩-៣០ ខែសីហា ឆ្នាំ២០១៣ ដែលមានតំណាង ២នាក់ក្នុងមួយស្ថាប័នដូចជា៖ វិស័យឯកជន គ្រឹះស្ថានអប់រំ អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ក្រុមសង្គមស៊ីវិល បណ្តាញសហគមន៍តំបន់ការពារ បណ្តាញសហគមន៍ព្រៃឈើ បណ្តាញសហគមន៍នេសាទ និងតំណាងជនជាតិដើមភាគតិច។ កិច្ចប្រជុំលើកទី១របស់ក្រុមប្រឹក្សាយោបល់ បានសំណូមពរ បញ្ជូនតំណាងក្រុមខ្លួន មកចូលរួមក្នុងកិច្ចប្រជុំក្រុមការងាររេដ+កម្ពុជា ដើម្បីចូលរួមមតិយោបល់ និងសុំមកណែនាំខ្លួន នៅក្នុងកិច្ចប្រជុំ។*

**ការសម្រេច**

- អនុញ្ញាតឲ្យតំណាង២នាក់ចូលរួមកិច្ចប្រជុំ ក្នុងនាមជាអ្នកសង្កេតការណ៍។ នៅពេលដែលមានប្រធានបទ ឬ មានបញ្ហាពាក់ព័ន្ធ ក្រុមការងារនឹងសុំឲ្យតំណាងក្រុមប្រឹក្សាយោបល់ដែលចូលរួម ធ្វើបទបង្ហាញ និងស្រាយបញ្ជាក់។ តំណាងដែលចូលរួមអាចចាកចេញពីអង្គប្រជុំបានពេលបញ្ចប់ប្រធានបទពាក់ព័ន្ធនឹងក្រុមប្រឹក្សាយោបល់។

## ៤- មតិបូកសរុបបិទអង្គប្រជុំ

*ឯកឧត្តម **ជា សំអាង** ជាប្រធានអង្គប្រជុំ បានបូកសរុប និងសង្ខេបលទ្ធផលថា៖ កិច្ចប្រជុំបានស្តាប់បទបង្ហាញស្តីពី យន្តការរេដ+ជាសកល និងវឌ្ឍនភាពរេដ+នៅកម្ពុជា។ បានពិភាក្សានិងអនុម័តលក្ខខ័ណ្ឌ*

ការងារក្រុមបច្ចេកទេស យុទ្ធសាស្ត្រផ្នែកទំនាក់ទំនងរេដ+ ទស្សនកិច្ចសិក្សានៅវៀតណាម ការឧបត្ថម្ភការចំណាយ និងការចូលរួមរបស់តំណាងក្រុមប្រឹក្សាយោបល់ក្នុងកិច្ចប្រជុំរបស់ក្រុមការងាររេដ+។

កិច្ចប្រជុំបានសម្រេចថា៖ ក្រុមបច្ចេកទេសទាំង៤ ត្រូវបញ្ចូលមន្ត្រីមកពីអគ្គនាយកដ្ឋានថាមពល ជាសមាជិកបន្ថែម និងកាត់ចេញអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែអាចអញ្ជើញឲ្យចូលរួមតាមការចាំបាច់។ ក្រុមការងារបច្ចេកទេស MRV/REL ត្រូវរក្សាដដែល បន្ទាប់ពីបញ្ចូលមន្ត្រីមកពីអគ្គនាយកដ្ឋានថាមពល និងកាត់ចេញអង្គការមិនមែនរដ្ឋាភិបាល ។ ជាបន្ថែមលើនេះ ក្រុមបច្ចេកទេសចែករំលែកផលប្រយោជន៍ ត្រូវបញ្ចូលមន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ជនបទជាសមាជិកបន្ថែម។ ដោយឡែក ក្រុមបច្ចេកទេសអនុវត្តគម្រោងគំរូ ត្រូវមានសមាជិកមកពីគ្រប់ស្ថាប័នឲ្យដូចក្រុមការងាររេដ+កម្ពុជា។ កិច្ចប្រជុំក៏បានសំណូមពរឲ្យមានការធ្វើបទបង្ហាញអំពីក្រុមបច្ចេកទេសMRV/REL ឲ្យបានស៊ីជម្រៅលើលក្ខណៈបច្ចេកទេស។

ក្រុមការងាររេដ+យល់ព្រមឲ្យលេខាធិការដ្ឋាន រៀបចំបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង និងធ្វើបទបង្ហាញ បន្ទាប់ពីបង្កើតបានសេចក្តីព្រាងយុទ្ធសាស្ត្រនេះ ដើម្បីឲ្យក្រុមការងាររេដ+កម្ពុជាអនុមត័។

ចំពោះទស្សនកិច្ចទៅប្រទេសវៀតណាម ក្រុមការងាររេដ+កម្ពុជាយល់ព្រមទៅតាមសំណើកម្មវិធី ប៉ុន្តែលេខាធិការដ្ឋានត្រូវធ្វើលិខិតអញ្ជើញឲ្យបាន នៅថ្ងៃទី១៣ ខែកញ្ញា និងផ្តល់កម្មវិធីលម្អិតបន្ថែម។

កិច្ចប្រជុំបានសម្រេចផ្តល់ការឧបត្ថម្ភចំណាយចំនួន៥០ដុល្លាអាមេរិកក្នុង១ខែ សម្រាប់ចំណាយទំនាក់ទំនង រៀបចំឯកសារប្រជុំ និងការធ្វើដំណើររបស់សមាជិកម្នាក់ៗ និងសំណូមពរទិញកុំព្យូទ័រ សម្រាប់ការបំពេញការងាររបស់ក្រុមការងាររេដ+។

កិច្ចប្រជុំបានអនុញ្ញាតឲ្យតំណាងក្រុមប្រឹក្សាយោបល់ ២នាក់ ចូលរួមកិច្ចប្រជុំក្រុមការងាររេដ+ ក្នុងនាមជាអ្នកសង្កេតការណ៍ ដោយអាចធ្វើបទបង្ហាញលើប្រធានបទពាក់ព័ន្ធ និងអាចចាកចេញពីអង្គប្រជុំបានប្រសិនបើយល់ថាភារកិច្ចត្រូវបានបញ្ចប់។

ចុងបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ និងបានបញ្ជាក់ថាកិច្ចប្រជុំលើកទី២ នឹងធ្វើឡើងនៅ៖ **ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣។**

**អ្នកធ្វើកំណត់ហេតុ**

For

**ប្រធានអង្គប្រជុំ**

បានឃើញ និងឯកភាព

កញ្ញា ធី ហៀង

មន្ត្រីទំនាក់ទំនង លេខាធិការដ្ឋានរេដ+កម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
Kingdom of Cambodia
**ជាតិ សាសនា ព្រះមហាក្សត្រ**
Nation Religion and King

## កំណត់បង្ហាញរឿង (Activity Note)

| | |
|---|---|
| **កម្មវត្ថុ (Objective):** | សុំហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំក្រុមការងាររេដ+កម្ពុជា នៅថ្ងៃទី១១-កញ្ញា-២០១៣ នៅសណ្ឋាគារ សូហ្វីតែលភូគីត្រាភ្នំពេញ |
| **យោង(Reference):** | Output 1.1 សកម្មភាព 1.1b : កិច្ចប្រជុំក្រុមការងាររេដ+កម្ពុជា |

☐ **ការប្រញាប់ (Urgent)**

| | | |
|---|---|---|
| ☐ទទ.☐គណ.☐រប.☐សស.☐លក.☐បទ<br>☐ CTA ☐ MRV | ☐ពិនិត្យ ☐ផ្តល់មតិ ☐មុខការ<br>☐ឯកសារ ☐ជូនជ្រាប ☐សម្រេច | |

**យោបល់មន្ត្រីជំនាញ (Comment/Activity Note by Technical Staff)**

- ក្រុមការងាររេដ+កម្ពុជា បានរៀបចំកិច្ចប្រជុំនៅថ្ងៃទី១១-កញ្ញា-២០១៣ នៅសណ្ឋាគារ សូហ្វីតែលភូគីត្រាភ្នំពេញ
- នៅថ្ងៃទី១៦-១៧ ខែកញ្ញា ឆ្នាំ២០១៣ លេខាធិការដ្ឋាន បានរៀបចំសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំ រួមទាំងឯកសារភ្ជាប់ និងផ្ញើជូនសមាជិកក្រុមការងាររេដ+កម្ពុជា ដើម្បីពិនិត្យ និងកែសម្រួល ។
- ដោយពុំមានការផ្តល់យោបល់ លេខាធិការដ្ឋាន បានបោះពុម្ពកំណត់ហេតុកិច្ចប្រជុំ រួមទាំងឯកសារភ្ជាប់ ដើម្បីសុំហត្ថលេខាពីប្រធានអង្គប្រជុំ។
- ដើម្បីធានាថាកំណត់ហេតុនេះបានគោរពតាមការសម្រេចក្នុងកិច្ចប្រជុំ ធីហៀង គឹមហ៊ី ធីតា បានពិនិត្យ និងកែសម្រួល។
- ប្រធានលេខាធិការដ្ឋានបានជួយពិនិត្យបន្ថែមដូចមាន initial លើកំណត់ហេតុ។

**ដូច្នេះសូមលោកប្រធានគម្រោងជួយពិនិត្យ និងផ្តល់យោបល់លើកំណត់ហេតុកិច្ចប្រជុំនេះ**

ធីតា

០២ ខែសីហា ឆ្នាំ២០១៣ លន់ គឹមហ៊ី, អ្នកសម្របសម្រួលកម្មវិធី

| យោបល់អនុប្រធានលេខាធិការដ្ឋាន (Comment by Deputy Chair of CRST) | យោបល់ប្រធានលេខាធិការដ្ឋាន (Comment by Chair of CRST) |
|---|---|
| Mr. Kamal, VHRTS. mission abroad from 07 → 10 october. 2013 as attached email | |

| យោបល់អនុប្រធានកម្មវិធីជាតិUN-REDDកម្ពុជា (Comment by Deputy National Programme Director) | យោបល់ប្រធានកម្មវិធីជាតិUN-REDDកម្ពុជា (Comment by National Programme Director) |
|---|---|
| | |

## Thida Pan

**From:** Thida Pan
**Sent:** Tuesday, October 08, 2013 1:51 PM
**To:** Huort Teng; tenghuort@yahoo.com; Kimhy Lun
**Subject:** FW: Interview Admin asst candidates 8 Oct 13

FYI

**From:** kamal uy [mailto:kamaluy@yahoo.com]
**Sent:** Sunday, October 06, 2013 10:34 AM
**To:** Thida Pan; Vathana Khun (vathana.khun@gmail.com); Mr. Bun Racy
**Cc:** samangfa@gmail.com; kimnongmoe@yahoo.com; Kimhy Lun
**Subject:** Re: Interview Admin asst candidates 8 Oct 13

Dear Thida and panel members,
Thank you very much for information and well-prepared questions.
It is very regret for me to inform you that I will not be able to participate in this interview panel as I have mission to Manila from 7-10 October 2013 to talk about Greenhouse Gas inventory.
In this current circumstance, I urge to look for some one to be an alternative to join the interview panel.
FYI and regards,
Kamal
**From:** Thida Pan <thida.pan@undp.org>
**To:** "kamaluy@yahoo.com" <kamaluy@yahoo.com>; "Vathana Khun (vathana.khun@gmail.com)" <vathana.khun@gmail.com>; Mr. Bun Racy <racymoly@yahoo.com>
**Cc:** "samangfa@gmail.com" <samangfa@gmail.com>; "kimnongmoe@yahoo.com" <kimnongmoe@yahoo.com>
**Sent:** Saturday, 5 October 2013, 7:40
**Subject:** RE: Interview Admin asst candidates 8 Oct 13

Dear Panel,

I would like to submit you the questionnaires for interviewing Admin Assistant. Instruction is included from pre interview, during interview and post interview.

Please read through the questionnaires and let me know if you have questions or comment to make change.

The interview will conduct in English. Panel will divide questions for interview. I will verbally brief you on the morning of Tuesday if you confirm the proposed time is ok.

Best,
thida

---

**From:** Thida Pan
**Sent:** Thursday, October 03, 2013 10:15 PM
**To:** kamaluy@yahoo.com; Vathana Khun (vathana.khun@gmail.com); 'Mr. Bun Racy'
**Cc:** samangfa@gmail.com; kimnongmoe@yahoo.com
**Subject:** Interview Admin asst candidates 8 Oct 13

Dear B.Vathana, Pu Kamal, and Pu Racy,

Reference to verbally confirmation by B. Vathana and Mr. Racy that they will be available to interview on 8 Oct 13 in the noon time, I would like to seek for Mr. Kamal confirmation if the schedule is convenience for you as I tried to call you but no answer.

I also attached excel file containing the list of 84 applicants and 10 shortlisted candidates.
Based on comment from panel we will only call the top 4 for interview only.

Please be informed that panel need to meet together in the morning of 8 October 13 to go through questionnaires and divide questions.

Look forward to your confirmation on above appointment. So that I can call applicants for interview.

Best,
thida

**CAMBODIA UN-REDD NATIONAL PROGRAMME**

UNDP PROJECT No. 00078446

(#40, Preah Norodom Blvd, Khan Daun Penh, Phnom Penh, Kingdom of Cambodia)

---

# លិខិតប្រគល់សិទ្ធ

ខ្ញុំបាទ **ឃុន វឌ្ឍនា** ប្រធានលេខាធិការដ្ឋាន REDD+ កម្ពុជា សូមសម្រេចប្រគល់សិទ្ធិជូន លោក **អ៊ុយ កាម៉ាល់** អនុប្រធានលេខាធិការដ្ឋាន REDD+ កម្ពុជា ដើម្បីទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងការងារលេខាធិការដ្ឋាន REDD+ កម្ពុជា ចាប់ពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ រហូតដល់ មានវត្តមានរូបខ្ញុំបាទដោយខ្ញុំបាទត្រូវបំពេញបេសកកម្មនៅក្រៅប្រទេស។

ភ្នំពេញ, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣

ប្រធានលេខាធិការដ្ឋាន REDD+ កម្ពុជា

ឃុន វឌ្ឍនា

<u>កន្លែងទទួល</u>

- លេខាធិការដ្ឋាន REDD+ កម្ពុជា
  "ដើម្បីជូនជ្រាប"
- លោក អ៊ុយ កាម៉ាល់
  "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ

# កិច្ចប្រជុំលើកទី១ក្រុមការងារ REDD+ កម្ពុជា

ទីកន្លែងប្រជុំ: សណ្ឋាគារ សូហ្វីតែលភូគីត្រា ភ្នំពេញ

កាលបរិច្ឆេទ: ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣

ពេលវេលា: ២:៣០- ៥:១៥នាទី រសៀល

## របៀបវារៈកិច្ចប្រជុំ

| | | |
|---|---|---|
| ២:៣០-២:៤៥ | - ចុះឈ្មោះអ្នកចូលរួម | - មន្ត្រីលេខាធិការដ្ឋាន |
| ២:៤៥-៣:០០ | - មតិចាប់ផ្តើមបើកអង្គប្រជុំ<br>- ការណែនាំខ្លួនរបស់សមាជិកក្រុមការងារREDD+កម្ពុជា<br>- ការថតរូបជាក្រុម | - ឯឧជាសំអាង |
| ៣:០០-៣:១៥ | - យន្តការរេដជាសាកល<br>- ការបង្ហាញពីវឌ្ឍនភាពREDD+ នៅកម្ពុជា និងសកម្មភាពជាអាទិភាព | - Mr. Peter Iversen<br>- លោកឃុនវឌ្ឍនា |
| ៣:១៥-៤:០០ | - ការអនុម័តលក្ខខ័ណ្ឌការងារក្រុមបច្ចេកទេសREDD+កម្ពុជា<br>➢ ក្រុមការងារបច្ចេកទេសធានាសុវត្ថិភាពរេដ+<br>(REDD+ safeguard Technical Team)<br>➢ ក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍<br>(REDD+ benefit sharing Technical Team)<br>➢ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ<br>(REDD+ Demonstration Technical Team)<br>➢ ក្រុមការងារបច្ចេកទេសMRV/REL<br>(REDD+ MRV/REL Technical Team) | <br>- លោកឈុនជីលុប<br>- Ms. Moeko ឬ Naomi<br>- លោកឡុងរតនៈកុមារ<br>- Mr. Peter Iversen<br>- លោកឡុងរតនៈកុមារ<br>- Mr. Peter Iversen<br>- លោកស្រី សាសូគីរ៉ា |
| ៤:០០-៤:១៥ | - សំណើឲ្យកម្មវិធីUN-REDD ដឹកនាំបង្កើតយុទ្ធសាស្ត្រផ្នែកទំនាក់ទំនងរេដ+កម្ពុជា(REDD+ Cambodia Communication Strategy) | កញ្ញា ធី ហៀង |
| ៤:១៥-៤:៣០ | - ទស្សនៈកិច្ចសិក្សានៅវៀតណាម | - លោក តុលសុខជា |
| ៤:៣០-៤:៤០ | - តម្រូវការចំណាយប្រចាំខែសម្រាប់ការងារទំនាក់ទំនងការរៀបចំឯកសារប្រជុំ និងការធ្វើដំណើរក្រុមការងារREDD+កម្ពុជា | - លោកស្រី ប៉ាន់ធីតា |
| | - លទ្ធផលជ្រើសរើសតំណាងក្រុមប្រឹក្សាយោបល់ | - កញ្ញា ធី ហៀង |
| ៤:៤០-៤:៥០ | - ផ្សេងៗ៖ការលើកទឹកចិត្តក្រុមការងារបច្ចេកទេស | - លោក អ៊ុយកាម៉ាល |
| ៤:៥០-៥:០០ | - មតិបូកសរុបបិទអង្គប្រជុំ | - ឯឧជាសំអាង |
| ៥:០០-៥:១៥ | - សម្រាកអាហារសម្រន់ | |

# កិច្ចប្រជុំលើកទី១ក្រុមការងារ REDD+ កម្ពុជា

*ទីកន្លែងប្រជុំ:* សណ្ឋាគារ សូហ្វីតែលភូគីត្រា ភ្នំពេញ

*កាលបរិច្ឆេទ:* ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣

*ពេលវេលា:* ២:៣០- ៥:១៥នាទី រសៀល

## របៀបវារៈកិច្ចប្រជុំ

| | | |
|---|---|---|
| ២:៣០-២:៤៥ | - ចុះឈ្មោះអ្នកចូលរួម | - មន្ត្រីលេខាធិការដ្ឋាន |
| ២:៤៥-៣:០០ | - មតិចាប់ផ្តើមបើកអង្គប្រជុំ<br>- ការណែនាំខ្លួនរបស់សមាជិកក្រុមការងារREDD+កម្ពុជា<br>- ការថតរូបជាក្រុម | - ឯឧជា សំអាង |
| ៣:០០-៣:១៥ | - យន្តការរេដជាសាកល<br>- ការបង្ហាញពីវឌ្ឍនភាពREDD+ នៅកម្ពុជា និងសកម្មភាពជាអាទិភាព | - Mr. Peter Iversen<br>- លោកឃុនវឌ្ឍនា |
| ៣:១៥-៤:០០ | - ការអនុម័តលក្ខខ័ណ្ឌការងារក្រុមបច្ចេកទេសREDD+កម្ពុជា<br>➢ ក្រុមការងារបច្ចេកទេសធានាសុវត្ថិភាពរេដ+<br>( REDD+ safeguard Technical Team )<br>➢ ក្រុមការងារបច្ចេកទេសចែករម្លែកផលប្រយោជន៍<br>( REDD+ benefit sharing Technical Team )<br>➢ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ<br>( REDD+ Demonstration Technical Team )<br>➢ ក្រុមការងារបច្ចេកទេសMRV/REL<br>( REDD+ MRV/REL Technical Team ) | <br>- លោកឈុនជីលុច<br>- Ms. Moeko ឬ Naomi<br>- លោកឡុងរតនៈកុមារ<br>- Mr. Peter Iversen<br>- លោកឡុងរតនៈកុមារ<br>- Mr. Peter Iversen<br>- លោកស្រី សាសូភីរ៉ា |
| ៤:០០-៤:១៥ | - សំណើឲ្យកម្មវិធី UN-REDD ដឹកនាំបង្កើតយុទ្ធសាស្ត្រផ្នែកទំនាក់ទំនងរេដ+កម្ពុជា ( REDD+ Cambodia Communication Strategy ) | កញ្ញា ធី ហៀង |
| ៤:១៥-៤:៣០ | - ទស្សនៈកិច្ចសិក្សានៅវៀតណាម | - លោក តុលសុខជា |
| ៤:៣០-៤:៤០ | - តម្រូវការចំណាយប្រចាំខែសម្រាប់ការងារទំនាក់ទំនងការរៀបចំឯកសារប្រជុំ និងការធ្វើដំណើរក្រុមការងារREDD+កម្ពុជា | - លោកស្រី ប៉ាន់ធីតា |
| | - លទ្ធផលជ្រើសរើសតំណាងក្រុមប្រឹក្សាយោបល់ | - កញ្ញា ធី ហៀង |
| ៤:៤០-៤:៥០ | - ផ្សេងៗៈការលើកទឹកចិត្តក្រុមការងារបច្ចេកទេស | - លោក អ៊ុយកាម៉ាល |
| ៤:៥០-៥:០០ | - មតិបូកសរុបបិទអង្គប្រជុំ | - ឯឧជា សំអាង |
| ៥:០០-៥:១៥ | - សម្រាកអាហារសម្រន់ | |

Annex 2

UN-REDD
PROGRAMME

## Cambodia UN-REDD National Programme

(#40, Preah Norodom Blvd, Khan Daun Penh, Phnom Penh, Kingdom of Cambodia)

# កិច្ចប្រជុំលើកទី១ក្រុមការងារ REDD+ កម្ពុជា

Venue: Sofitel Phnom Penh Phukeethra
Date: 11 September, 2013

| ល.រ No | ឈ្មោះ Name | ភេទ Sex | តួនាទី Position | ស្ថាប័ន Organization | លេខទូរស័ព្ទ Phone Number | អ៊ីម៉ែល E-mail | ហត្ថលេខា Signature |
|---|---|---|---|---|---|---|---|
| 1 | [illegible] | ប | [illegible] | [illegible] | | | |
| 2 | Naomi Matsue | F | co-benefit | FA-JICA | 012 909548 | matsue.naomi@gmail.com | |
| 3 | Ches Sopheap | F | Office Manager | FA | 0977779898 | chsopheap16@gmail.com | |
| 4 | [illegible] | [illegible] | [illegible] | [illegible] | 0888238824 | PhannPhearum@gmail.com | |
| 5 | Moeko Saito-Jensen | F | programme Analyst | UNDP | 017 868 835 | moeko.saito-jensen@undp.org | |
| 6 | CHAN SOMANTA | M. | | FA | 0977777058 | Chan.somanta@gmail.com | |
| 7 | [illegible] | F | [illegible] | RTS | 012960436 | thida.pan@undp.org | |
| 8 | [illegible] | M | [illegible] | RTS | 096890008 | huottong@undp.org | |

Annex 2

| ល.រ<br>No | ឈ្មោះ<br>Name | ភេទ<br>Sex | តួនាទី<br>Position | ស្ថាប័ន<br>Organization | លេខទូរស័ព្ទ<br>Phone Number | អ៊ីម៉ែល<br>E-mail | ហត្ថលេខា<br>Signature |
|---|---|---|---|---|---|---|---|
| 9 | [illegible] | ប. | [illegible] | MRD | 012925888 | chhayheang.mrd@gmail.com | [signature] |
| 10 | Sar sophyra | F. | | DFC | 012488339 | sophyra.sar@gmail.com | [signature] |
| 11 | Shigeru Ono | M | LEADER | JICA TA TEAM | | | [signature] |
| 12 | CHHUM. Sovanny | ប | UNDP | Proj. Analyst | 012919014 | chhum.sovanny@undp.org | [signature] |
| 13 | Lun. kimhy | M | PC. | DTS | | kimhy.lun@undp.org | [signature] |
| 14 | Kim Wony | M | DDG | MoG | | | [signature] |
| 15 | Heng Houy | M | ~~Aot~~ chief office | MoE | 012705260 | | [signature] |
| 16 | Long Ratanakoma | M | DD. | DFC/FA | | | [signature] |
| 17 | Bun Racy | M | Deputy Director | FIA | 095915567 | | [signature] |
| 18 | Tol Sokchea | M. | Training Officer | RECOFTC | 012322696 | | [signature] |
| 19 | Peou Vorleaky | F | DG | MIME | 012377869 | | [signature] |
| 20 | Chean Pe?? | M | | NCDDS. | | | [signature] |
| 21 | Sorn Sunsopheak | M | [illegible] | NCDDS | 012922123 | | [signature] |

Annex 2

| ល.រ No | ឈ្មោះ Name | ភេទ Sex | តួនាទី Position | ស្ថាប័ន Organization | លេខទូរស័ព្ទ Phone Number | អ៊ីម៉ែល E-mail | ហត្ថលេខា Signature |
|---|---|---|---|---|---|---|---|
| 22 | [illegible] | [illegible] | [illegible] | [illegible] | 0979764772 | | |
| 23 | Siv Cheang | F | Program officer | JICA | 095 888 68T | sivcheang.cm@jica.go.jp | |
| 24 | Omaliss KEO | M | Director DAFF | FA | 012755558 | omaliss@gmail.com | |
| 25 | SHISHIDO Kenichi | M | DDG | JICA HQ | | shishido.kenichi@jica.go.jp | |
| 26 | Tomoko Taira | F | Adviser | 〃 | | Taira.Tomoko@jica.go.jp | |
| 27 | H. Nakata | M | TA - DG | FA | 01223704P | | |
| 28 | vathana khun | M | CRTS | FA | 012686768 | | |
| 29 | Phy Heang | F | do | RTS. | 012500322 | | |
| 30 | Peter Iversen | M | Tech. Specialist | RTS. | | | |
| 31 | Chhun Delux | M | Tech-officer | RTS. | | | |
| 32 | Nguon Pheakkdey | M | | RTS. | | | |
| 33 | | | | | | | |
| 34 | | | | | | | |

# ក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍រេដ+

( REDD+ Benefit Sharing Technical Team )

( រេដ+៖ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរិលព្រៃឈើ )

## លក្ខខ័ណ្ឌការងារ

### ១. សាវតា

យន្តការអនាគតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរិលព្រៃឈើ( រេដ+) ដែលកំពុងរៀបចំតាមរយៈអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្តល់ឱកាសដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយកម្រិតនៃការរិចរឹលព្រៃឈើ និងជួយថែរក្សាការពារព្រៃធម្មជាតិ ក៏ដូចជាការបង្កើតព្រៃថ្មី។

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំដំណើរការផែនការត្រៀមលក្ខណៈសម្រាប់រេដ+ ដែលនាំទៅដល់ ការបង្កើតសំណើផែនការត្រៀមលក្ខណៈសម្រាប់រេដ+នៅកម្ពុជា (ផែនទីបង្ហាញផ្លូវ)។ ឯកសារនេះបង្ហាញថាតើកម្ពុជានឹងបង្កើត គោលនយោបាយ និងវិធានការអ្វីខ្លះដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់ រេដ+។

សមាសភាគសំខាន់ដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់រេដ+ គឺត្រូវមានប្រព័ន្ធចែករំលែកការទទួលផលប្រយោជន៍ជាវិជ្ជមាន សម្រាប់លទ្ធផលដែលសម្រេចបាន ក្នុងការកាត់បន្ថយការបញ្ចេញ ឬ ពង្រឹងការស្រូបយកឧស្ម័ន ដែលអាចរាយការណ៍បានតាមរបាយការណ៍ និងការផ្ទៀងផ្ទាត់ ដែលស្របតាមដំណើរការរបស់ UNFCCC ដែលបច្ចុប្បន្ននេះ នៅមិនទាន់បានសម្រេចនៅឡើយនៅក្នុងការចរចារជាលក្ខណៈអន្តរជាតិ។ ផលប្រយោជន៍ ឬ ការលើកទឹកចិត្តអាចយល់ថាទាំងសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ដូចជាការធ្វើឲ្យប្រសើឡើងនូវសិទ្ធិ និងបន្តឲ្យប្រើប្រាស់ធនធានជាដើម។

ប្រព័ន្ធចែករំលែកផលប្រយោជន៍នេះ ត្រូវមានសមធ៌ម ផ្តល់ការលើកទឹកចិត្តដល់ការចូលរួម មានតម្លាភាព និង មានប្រសិទ្ធិភាព។ ប្រព័ន្ធចែករំលែកផលប្រយោជន៍នេះ ត្រូវយកចិត្តទុកដាក់លើបទពិសោធន៍ដែលធ្លាប់បានអនុវត្តនាពេលបច្ចុប្បន្ន និងកន្លងមកនៅកម្ពុជា ក៏ប៉ុន្តែអាចនឹងមានផលវិបាក ដល់វិធីសាស្ត្រអនុវត្តនៅថ្នាក់ក្រោមជាតិ ដែលកើតចេញពីការសាកល្បងគម្រោងផ្តល់ហិរញ្ញប្បទាន តាមរយៈទីផ្សារកាបូនស្ម័គ្រចិត្ត ដែលជាវិធីសាស្ត្របណ្តោះអាសន្ន មុននឹងឈានទៅដល់ការអនុវត្តនៅថ្នាក់ជាតិ ដែលស្ថិតក្រោមក្របខ័ណ្ឌការងាររបស់ UNFCCC ។

### ២. គោលបំណង

គោលបំណងរបស់ក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍រេដ+ គឺធានាថាមេរៀន និងបទពិសោធន៍ស្តីពីប្រព័ន្ធចែករំលែកផលប្រយោជន៍ នាពេលបច្ចុប្បន្ន និងកន្លងមកនៅកម្ពុជា ត្រូវបានសិក្សាសម្រាប់សេចក្តីត្រូវការក្នុងបរិបទ រេដ+ និងមេរៀនជាបទពិសោធន៍ ដែលទទួលបានពីបណ្តាប្រទេសនានាត្រូវបានរួមបញ្ចូល ដើម្បីផ្តល់ជាអនុសាសន៍ដល់ការរៀបចំប្រព័ន្ធចែករំលែកផលប្រយោជន៍សម្រាប់ រេដ+ នៅកម្ពុជា ។

### ៣. សមាជិកភាព

ក្រុមបច្ចេកទេសមានសមាជិកតំណាងមកពី៖

- ក្រសួងមហាផ្ទៃ ចំនួន១នាក់(អគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន)
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន១នាក់(អគ្គនាយកដ្ឋាន ថាមពល)
- ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន១នាក់

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ១នាក់,
- ការិយាល័យពាក់ព័ន្ធ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលជលផល១នាក់
- សមាជិកក្រុមប្រឹក្សាយោបល់ រេដ+ កម្ពុជា ចំនួន៣នាក់ ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ (ក្រុមប្រឹក្សាយោបល់នឹងចាត់តាំងសមាជិកក្រុមមកចូលរួម)
- លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ចំនួន២នាក់ នឹងត្រូវចាត់តាំងដោយ ប្រធានលេខាធិការដ្ឋាន។

សមាជិកទាំងអស់ត្រូវចាត់តាំងតំណាងមកចូលរួមជំនួសក្នុងកិច្ចប្រជុំនានា ប្រសិនបើមានធុរៈចាំបាច់។ យោងតាមតម្រូវការជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ នឹងអាចអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំ។

## ៤. ប្រតិបត្តិការ

ក្រុមការងារបច្ចេកទេសនេះត្រូវជួបប្រជុំប្រចាំខែ។ ប្រធានក្រុមការងារបច្ចេកទេស នឹងត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុម និងអនុម័តដោយប្រធានលេខាធិការដ្ឋាន។ ប្រធានក្រុមការងារបច្ចេកទេស ជាប្រធានដឹកនាំកិច្ចប្រជុំ។ សមាជិកដែលមកពីលេខាធិការដ្ឋានម្នាក់ នឹងត្រូវតែងតាំងជាលេខាធិការ របស់ក្រុមការងារបច្ចេកទេស ។ លេខាធិការត្រូវជានាថា លិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ដោយមានភ្ជាប់ឯកសារដែលត្រូវពិភាក្សា បានផ្ញើជូនដល់គ្រប់សមាជិក រយៈពេល១សប្តាហ៍មុនកិច្ចប្រជុំ។ លេខាធិការត្រូវផ្ញើសេចក្តីព្រាងកំណត់ ហេតុកិច្ចប្រជុំ ជូនគ្រប់សមាជិកក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ។ សមាជិក (ឬអ្នកជំនួស) ទាំងអស់ត្រូវផ្តល់យោបល់លើ សេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំក្នុងរយៈពេល៣ថ្ងៃ បន្ទាប់មកលេខាធិការ កែសម្រួលកំណត់ហេតុកិច្ចប្រជុំតាមការផ្តល់យោបល់ និងផ្ញើកំណត់ហេតុសម្រេចជូនគ្រប់សមាជិកក្រុមការងារបច្ចេកទេស។ កំណត់ហេតុកិច្ចប្រជុំត្រូវមាន កាលបរិច្ឆេទ ពេលវេលា ទីកន្លែង ប្រធានបទជាបន្តបន្ទាប់ក្នុងកិច្ចប្រជុំ និងផ្សព្វផ្សាយជាសាធារណៈ ជូនដល់គ្រប់អ្នកពាក់ព័ន្ធតាមរយៈការដាក់នៅក្នុងគេហទំព័រ រេដ+ កម្ពុជា ។

## ៥. ការធ្វើសេចក្តីសម្រេច

ក្រុមការងារបច្ចេកទេសនេះមិនមែនជាអ្នកធ្វើសេចក្តីសម្រេចទេ ប៉ុន្តែជាអ្នកផ្តល់អនុសាសន៍ដល់ក្រុមការងាររេដ+ កម្ពុជា និងលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ជារៀងរាល់ខែ។ អនុសាសន៍នានានឹងត្រូវធ្វើឡើង តាមគោលការណ៍នៃការឯកភាពមតិ។

## ៦. ការទទួលខុសត្រូវ

ក្រុមការងារបច្ចេកទេសនេះ ត្រូវធ្វើការជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីគាំទ្រដល់ការបង្កើតសំណើនានាពាក់ព័ន្ធនឹងប្រព័ន្ធចែករំលែកផលប្រយោជន៍ រេដ+ នៅកម្ពុជា។ ក្រុមការងារបច្ចេកទេស បង្កើតអនុសាសន៍ និងផ្តល់ជូនក្រុមការងារ រេដ+ កម្ពុជា តាមរយៈ៖

- សិក្សាពីលទ្ធភាព នៃអ្នកប្រើប្រាស់ និងអ្នកការពារ ដើម្បីធានាការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌
- ពិនិត្យមេរៀនជាបទពិសោធន៍ដែលទទួលបានពី គម្រោងសាកល្បងបង្ហាញ
- ពិនិត្យមេរៀនជាបទពិសោធន៍ដែលទទួលបានពី គម្រោងគ្រប់គ្រងធនធានធម្មជាតិ ដែលមានការចែករំលែកផលប្រយោជន៍
- សម្របសម្រួលជាមួយដៃគូដែលធ្វើការងារក្នុងវិស័យដូចគ្នា
- ពិនិត្យសំណើប្រព័ន្ធចែករំលែកផលប្រយោជន៍ រេដ+ នៅបណ្តាប្រទេសនានា
- ពិភាក្សាជាអ្នកឯកទេសពាក់ព័ន្ធ
- បង្កើតសំណើបឋម និងរៀបចំកិច្ចប្រឹក្សាយោបល់យ៉ាងទូលំទូលាយលើសំណើបឋមនេះ។

*ភារកិច្ចជាក់លាក់របស់ក្រុមបច្ចេកទេស៖*

- ការចូលរួមប្រជុំប្រចាំខែ
- ការពិនិត្យឯកសារ និងបទបង្ហាញនានា និងផ្តល់យោបល់ កែលម្អលើឯកសារ និងបទបង្ហាញទាំងនោះ
- ផ្តល់ជាជំនួយដល់ទីប្រឹក្សា និងបុគ្គលិក លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ក្នុងការអនុវត្តកិច្ចការរបស់ពួកគេ

- ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។

ដោយសារមានកិច្ចការងារជាច្រើនដែលត្រូវបំពេញ ក្រុមបច្ចេកទេសត្រូវបង្កើតផែនការការងារ និងមានកំណត់ទំហំការងារជាក់លាក់ដែលត្រូវសម្រេចឲ្យបាន ដោយមានការពិភាក្សាជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីចាត់អាទិភាពការងារ។

## ៧. ការធ្វើរបាយការណ៍

សមាជិកក្រុមបច្ចេកទេសនេះ ត្រូវទទួលខុសត្រូវធ្វើរបាយការណ៍ និងប្រឹក្សាយោបល់ជាមួយស្ថាប័នសាមី និងក្រុមគោលដៅរបស់ខ្លួន។ សមាជិកទាំងនេះអាចស្នើសុំឲ្យមានការផ្តល់ពេលវេលាជាបន្ថែមដើម្បីពិចារណាបញ្ហាជាក់លាក់នានា ប្រសិនបើយល់ថាបញ្ហាទាំងនោះមានសារៈសំខាន់ជាពិសេស ចំពោះស្ថាប័នរបស់ខ្លួន និងតម្រូវឲ្យមានការពិភាក្សាជាបន្ថែម។

ក្រុមការងារបច្ចេកទេស ត្រូវធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់ទៅលេខាធិការដ្ឋាន ក្រុមការងាររេដ+កម្ពុជា តាមរយៈលេខាធិការ ក្រុមការងារបច្ចេកទេសនេះ។

## ៨. រយៈពេល និងថេរវេលា

សមាជិកត្រូវធ្វើការប្រមាណជា ១ថ្ងៃ ទៅ ៣ថ្ងៃ ក្នុងមួយខែ អាស្រ័យលើសកម្មភាពដែលត្រូវអនុវត្ត។ ល័ក្ខខ័ណ្ឌប្រតិបត្តិនេះអាចស្នើសុំកែសម្រួល ដោយក្រុមការងារបច្ចេកទេស និងអនុម័តដោយក្រុមការងាររេដ+កម្ពុជា។

## ៩. ថវិកាគាំទ្រ

ការគាំទ្រថវិកា នឹងផ្តល់ដោយ កម្មវិធី UN-REDD និង គម្រោង FCPF (R-PP) ដោយយោងទៅតាមថវិកាដែលបានអនុម័តសម្រាប់ការចំណាយ នៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចការនានាដែលទាក់ទងនឹងតួនាទីទាំងនេះ។ ការគាំទ្រមកពីក្របខ័ណ្ឌការងារផ្សេងទៀតនឹងត្រូវពិចារណាផងដែរ៕

***

# ក្រុមការងារបច្ចេកទេសធានាសុវត្ថិភាពរេដ+

( REDD+ safeguards Technical Team )

( រេដ+៖ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ )

## លក្ខខ័ណ្ឌការងារ

## ១. សាវតា

យន្តការអនាគតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ( រេដ+) ដែលកំពុងរៀបចំតាមរយៈអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្តល់ឱកាសដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយកម្រិតនៃការរិចរឹលព្រៃឈើ និងជួយថែរក្សាការពារព្រៃធម្មជាតិ ក៏ដូចជាការបង្កើតព្រៃថ្មី។

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញនូវការគាំទ្រក្នុងការបង្កើតឲ្យមានវិធីសាស្រ្តសម្រាប់អនុវត្ត រេដ+ ដោយបានអនុម័តឲ្យមានគម្រោងសាកល្បងចំនួន២នៅឆ្នាំ២០០៨ និងឆ្នាំ២០០៩។ បន្ទាប់ពីនេះ មានគម្រោងសាកល្បងជាច្រើន បានចាប់ផ្តើមបង្កើត និងអនុវត្ត ដែលមានវឌ្ឍនភាពស្ថិតក្នុងដំណាក់កាលខុសៗគ្នា។ នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំដំណើរការផែនការត្រៀមលក្ខណៈសម្រាប់ រេដ+ ដែលនាំទៅដល់ការបង្កើតសំណើផែនការត្រៀមលក្ខណៈសម្រាប់ រេដ+ នៅកម្ពុជា (ផែនទីបង្ហាញផ្លូវ)។ ឯកសារនេះបង្ហាញថាតើកម្ពុជានឹងបង្កើត គោលនយោបាយ និងវិធានការអ្វីខ្លះដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់ រេដ+ ។

ប្រព័ន្ធធានាសុវត្ថិភាពរេដ+ (REDD+ Safeguards) ត្រូវបានបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងកាន់គុន(Cancun Agreements) ដើម្បីធានាថា សកម្មភាពនានាក្នុងក្របខ័ណ្ឌ រេដ+ មិនបង្កផលប៉ះពាល់អវិជ្ជមានមកលើសង្គម ឬ បរិស្ថានឡើយ។ ប្រព័ន្ធធានាសុវត្ថិភាពរេដ+ ត្រូវបានចាត់ទុកជារួមថាជា គោលនយោបាយ ឬ វិធានការនានា ដែលមានគោលដៅធ្វើឲ្យមានឥទ្ធិពលដោយផ្ទាល់ ឬ ប្រយោលទៅលើ សហគមន៍ និងប្រព័ន្ធអេកូឡូស៊ី តាមរយៈការកំណត់អត្តសញ្ញាណ ការវិភាគ និងនៅទីបំផុត គឺមានមុខងារដើម្បីគ្រប់គ្រងហានិភ័យ និងឱកាសនានា។ ប្រសិនបើបានបង្កើតឡើង និងយកមកប្រើប្រាស់ដោយសមស្រប ប្រព័ន្ធធានាសុវត្ថិភាពរេដ+ នេះអាចជួយ រេដ+ក្នុងការផ្តល់នូវពហុប្រយោជន៍ជាច្រើន។ នៅពេលដែលប្រព័ន្ធធានាសុវត្ថិភាពរេដ+នេះ ត្រូវបានចាត់ទុកថាជាគោលការណ៍ "មិនបង្កគ្រោះថ្នាក់" ដូច្នេះនៅពេលអនុវត្តសកម្មភាព រេដ+ នឹងផ្តល់នូវឱកាសដើម្បីទទួលផលបានច្រើនជាងល័ក្ខខណ្ឌធម្មតា នឹងសមស្របតាមគោលគំនិតអំពីពហុប្រយោជន៍ ។ ឧទាហរណ៍៖ សកម្មភាពនានាដែលទាក់ទងនឹង រេដ+ មិនត្រឹមតែការពារព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចកែលម្អគុណភាពទឹក ដែលហូរចេញមកតាមទន្លេនានាពីក្នុងតំបន់នោះ និងកាត់បន្ថយហានិភ័យ នៃជំនន់ដីគំហុកបណ្តាលពីទឹកយ៉ាងច្រើនដែលហូរយ៉ាងរហ័សនៅលើផ្ទៃដីផងដែរ។

កិច្ចព្រមព្រៀងកាន់គុន( Cancun Agreements )មានឧបសម្ព័ន្ធស្តីពីប្រព័ន្ធធានាសុវត្ថិភាពរេដ+ចំនួន៧ ដែលត្រូវគោរព និងដោះស្រាយតាមរយៈនៃការអនុវត្ត រេដ+ ។ តាមសេចក្តីសម្រេចនៃកិច្ចព្រមព្រៀងស្តីពី រេដ+ នៅកូបទី១៧ ( COP17 )នាទីក្រុង ដ័របែន ( DURBAN ) បានផ្តល់សេចក្តីណែនាំបន្ថែមអំពីប្រព័ន្ធផ្តល់ព័ត៌មាន ថាតើប្រព័ន្ធធានាសុវត្ថិភាពរេដ+ត្រូវបានគោរព និងដោះស្រាយដោយរបៀបណា។

ការផ្តួចផ្តើមជាអន្តរជាតិជាច្រើន បានបង្កើតឡើងនូវបទដ្ឋាននានាដូចជា និយមន័យ ទំហំការងារ និងវិធីសាស្រ្តសម្រាប់វាស់វែង ឬ ត្រួតពិនិត្យលើប្រព័ន្ធធានាសុវត្ថិភាពរេដ+ មានលក្ខណៈស្រដៀងគ្នានឹងបទដ្ឋាន រេដ+ ដែលមាននៅក្នុងកិច្ចព្រមព្រៀងកាន់គុនដែរ។ ដូច្នេះតម្រូវការជាក់លាក់នៃបទដ្ឋានប្រព័ន្ធធានាសុវត្ថិភាព គឺអាស្រ័យតាមប្រភពថវិកាគាំទ្រ។ ឧទាហរណ៍៖ គោលការណ៍ និង លក្ខណៈវិនិច្ឆ័យបរិស្ថាន-សង្គម(SEPC) របស់កម្មវិធី UN-REDD ការផ្ទៀងផ្ទាត់បទដ្ឋានកាបូន (VCS) សម្ព័ន្ធសហគមន៍ស្តីពីអាកាសធាតុ និងជីវចម្រុះ( CCBA ) ការសិក្សាពីយុទ្ធសាស្រ្តបរិស្ថាន-សង្គម ( SESA )។

ប្រទេសនីមួយៗ ត្រូវបង្កើតប្រព័ន្ធធានាសុវត្ថិភាពបរិស្ថាន-សង្គម ឲ្យបានសមស្រប និងមានវិធីសាស្ត្រដើម្បីធានាថា ពហុប្រយោជន៍ត្រូវបានដាក់បញ្ចូលឲ្យមានសង្គហតិភាពជាមួយកិច្ចព្រមព្រៀងជាអន្តរជាតិ ដំណើរការត្រូវមានការប្រឹក្សាយោបល់ឲ្យបានទូលំទូលាយ និងមានការទទួលស្គាល់ជាសាធារណៈ និងបានកាត់បន្ថយជាអតិបរមានូវហានិភ័យទៅដល់បរិស្ថាន-សង្គម និងអភិបាលកិច្ច និងស្របពេលជាមួយគ្នានេះ អាចបញ្ចៀសបាននូវការចំណាយខ្ពស់ក្នុងពេលអនុវត្ត។

ការបង្កើត រេដ+ នៅកម្ពុជា នឹងមានផលប៉ះពាល់ទៅលើអ្នកជាប់ពាក់ព័ន្ធជាច្រើន។ ផែនការប្រឹក្សាយោបល់និងការចូលរួមត្រូវបានបង្កើតឡើង នៅក្នុងដំណើការបង្កើតផែនទីបង្ហាញផ្លូវ រេដ+ កម្ពុជា។ ផែនការនេះនឹងត្រូវអភិវឌ្ឍន៍បន្ថែមទៀត ដើម្បីអនុញ្ញាតឲ្យអ្នកជាប់ពាក់ព័ន្ធអាចចូលរួមចាត់ចែង ក្នុងដំណើការត្រៀមលក្ខណៈសម្រាប់ការអនុវត្ត រេដ+ និងផ្តល់ឲ្យអ្នកពាក់ព័ន្ធ ទទួលបានព័ត៌មានអំពី រេដ+ និងដំណើការត្រៀមលក្ខណៈសម្រាប់ការអនុវត្ត រេដ+ ។

ការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺជាប្រព័ន្ធធានាសុវត្ថិភាពមួយ នៅក្នុងកិច្ចព្រមព្រៀងកាន់គុណផងដែរ។

## ២. គោលបំណង

គោលបំណងរបស់ក្រុមការងារបច្ចេកទេសស្តីពីប្រព័ន្ធធានាសុវត្ថិភាពរេដ+គឺគាំទ្រការសិក្សា និងបង្កើតវិធីសាស្ត្រ សម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដ+ដោយរួមបញ្ចូល ការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធ និងការចូលរួម ទៅក្នុងកម្មវិធី រេដ+ កម្ពុជា ។

## ៣. សមាជិកភាព

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពមានសមាជិកមកពី៖

- ក្រសួងមហាផ្ទៃ ចំនួន១នាក់(អគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន)
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន១នាក់(អគ្គនាយកដ្ឋាន ថាមពល)
- ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ២នាក់,
- ការិយាល័យពាក់ព័ន្ធ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលជលផល១នាក់
- សមាជិកក្រុមប្រឹក្សាយោបល់ រេដ+ កម្ពុជា ចំនួន៣នាក់ ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ (ក្រុមប្រឹក្សាយោបល់នឹងចាត់តាំងសមាជិកក្រុមមកចូលរួម)
- លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ចំនួន២នាក់ នឹងត្រូវចាត់តាំងដោយ ប្រធានលេខាធិការដ្ឋាន។

សមាជិកទាំងអស់ត្រូវចាត់តាំងតំណាងមកចូលរួមជំនួសក្នុងកិច្ចប្រជុំនានា ប្រសិនបើមានធុរៈចាំបាច់។ យោងតាមតម្រូវការជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ នឹងអាចអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំ។

## ៤. ប្រតិបត្តិការ

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដ+ត្រូវជួបប្រជុំប្រចាំខែ។ ប្រធានក្រុមការងារបច្ចេកទេស នឹងត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុម និងអនុម័តដោយប្រធានលេខាធិការដ្ឋាន។ ប្រធានក្រុមការងារបច្ចេកទេស ជាប្រធានដឹកនាំកិច្ចប្រជុំ។ សមាជិកដែលមកពីលេខាធិការដ្ឋានម្នាក់ នឹងត្រូវតែងតាំងជាលេខាធិការ របស់ក្រុមការងារបច្ចេកទេស ។ លេខាធិការក្រុមបច្ចេកទេសត្រូវធានាថា លិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ដោយមានភ្ជាប់ឯកសារដែលត្រូវពិភាក្សា បានផ្ញើជូនដល់គ្រប់សមាជិករយៈពេល១សប្តាហ៍មុនកិច្ចប្រជុំ។ លេខាធិការត្រូវផ្ញើសេចក្តីព្រាងកំណត់ ហេតុកិច្ចប្រជុំ ជូនគ្រប់សមាជិកក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ។ សមាជិក(ឬអ្នកជំនួស)ទាំងអស់ ត្រូវផ្តល់យោបល់លើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំក្នុងរយៈពេល៣ថ្ងៃ បន្ទាប់មកលេខាធិការ កែសម្រួលកំណត់ហេតុកិច្ចប្រជុំតាមការផ្តល់យោបល់ និងផ្ញើកំណត់ហេតុសម្រេចជូនគ្រប់សមាជិកក្រុមការងារបច្ចេកទេស។ កំណត់ហេតុកិច្ចប្រជុំត្រូវមាន កាលបរិច្ឆេទ ពេលវេលា ទីកន្លែង ប្រធានបទជាបន្តបន្ទាប់ក្នុងកិច្ចប្រជុំ និងផ្សព្វផ្សាយជាសាធារណៈ ជូនដល់គ្រប់អ្នកពាក់

ព័ន្ធ តាមរយៈក្រុមប្រឹក្សាយោបល់ និងដាក់នៅក្នុងគេហទំព័រ រេដ+ កម្ពុជា ។ ក្រុមការងារបច្ចេកទេស នឹងមានការជួយគាំទ្របច្ចេកទេស ពីអ្នកឯកទេសអន្តរជាតិ និងទីប្រឹក្សាបច្ចេកទេសអន្តរជាតិផងដែរ។

## ៥. ការធ្វើសេចក្តីសម្រេច

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដ+នេះមិនមែនជាអ្នកធ្វើសេចក្តីសម្រេចទេ ប៉ុន្តែជាអ្នកផ្តល់អនុសាសន៍ដល់ក្រុមការងារ រេដ+ កម្ពុជា និង លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ជារៀងរាល់ខែ។ អនុសាសន៍នានានឹងត្រូវធ្វើឡើង តាមគោលការណ៍នៃការឯកភាពមតិ។

## ៦. ការទទួលខុសត្រូវ

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដ+នេះ ត្រូវធ្វើការជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីគាំទ្រដល់ការបង្កើតវិធីសាស្រ្តនានាសម្រាប់រៀបចំប្រព័ន្ធការពារសុវត្ថិភាពបរិស្ថាន-សង្គម ដោយរួមបញ្ចូលឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធឲ្យបានពេញលេញ មានប្រសិទ្ធិភាព និងធានាបាននូវពហុប្រយោជន៍។ រៀបចំដំណើរការប្រឹក្សាយោបល់ ត្រូវសម្រេចឲ្យបាននូវការគាំទ្រ និងទទួលយកជាទូទៅអំពីវិធីសាស្រ្តប្រឹក្សាយោបល់នេះ។ ការទទួលខុសត្រូវនេះរួមមាន៖

- ការរៀបចំ និងកែសម្រួលផែនការលម្អិត
- អនុវត្តសកម្មភាពបង្កើនការយល់ដឹងស្តីពីប្រព័ន្ធធានាសុវត្ថិភាពរេដ
- អនុវត្តសកម្មភាពកសាងសមត្ថភាពស្តីពីប្រព័ន្ធធានាសុវត្ថិភាពរេដ
- អនុវត្តការសិក្សា ឬ ចាត់ចែងការសិក្សា ពាក់ព័ន្ធនិងវិធីសាស្រ្តក្នុងការរៀបចំប្រព័ន្ធធានាសុវត្ថិភាពបរិស្ថាន-សង្គម ដែលមានស្រាប់នៅក្នុង និងក្រៅប្រទេស។
- អនុវត្តផ្ទាល់ ឬ ជួយសិក្សា គោលការណ៍និងលក្ខណៈវិនិច្ឆ័យប្រព័ន្ធធានាសុវត្ថិភាពរេដ ដែលមានស្រាប់ (ឧទាហរណ៍ UNFCCC, UN-REDD, FCPF, CCBA and CI)
- អនុវត្តផ្ទាល់ ឬ ជួយសិក្សា បទពិសោធន៍អនុវត្តប្រព័ន្ធធានាសុវត្ថិភាព ដែលមានស្រាប់នៅក្នុង និងក្រៅប្រទេស
- អនុវត្តផ្ទាល់ ឬ ជួយវិភាគ ច្បាប់ គោលនយោបាយ វិធាននានា ដែលដោះស្រាយបញ្ហាពាក់ព័ន្ធនឹងប្រព័ន្ធធានាសុវត្ថិភាព
- អនុវត្តផ្ទាល់ ឬ ជួយចាត់ចែងការសិក្សាស្តីពីសក្តានុពលរបស់រេដ និងពហុប្រយោជន៍
- សម្របសម្រួលជាមួយដៃគូនានា (ឧទា: អង្គការមិនមែនរដ្ឋាភិបាលផ្តល់ជំនួយអន្តរជាតិ)ដែលធ្វើការងារក្នុងវិស័យដូចគ្នា
- បង្កើតសំណើស្តីពី សមាសធាតុ និងវិធីសាស្រ្តថ្នាក់ជាតិ ក្នុងការរៀបចំប្រព័ន្ធធានាសុវត្ថិភាពរេដជាតិ ដោយរួមបញ្ចូលបញ្ហា FPIC និងពហុប្រយោជន៍
- បង្កើតសំណើស្តីពី ដំណើរការ វិធាន និងនិតិវិធីជាក់លាក់ ក្នុងការដោះស្រាយបញ្ហា ពាក់ព័ន្ធនឹងសមាសធាតុនានានៅក្នុងប្រព័ន្ធធានាសុវត្ថិភាពរេដ(ដូចជាបញ្ហា FPIC) ដែលបានកំណត់ខាងលើ
- បង្កើតសំណើស្តីពីការត្រួតពិនិត្យ និងរាយការណ៍ ថាតើប្រព័ន្ធធានាសុវត្ថិភាពរេដបានដោះស្រាយ និងគោរពដោយរបៀបណា ដោយយោងតាមកិច្ចព្រមព្រៀង UNFCCC
- បង្កើតសំណើស្តីពីយន្តការដោះស្រាយទំនាស់ ដើម្បីកំណត់ និងដោះស្រាយ នូវទំនាស់ដែលកើតមានឡើងដោយសាររេដឲ្យមានប្រសិទ្ធភាព
- ផ្តល់ការណែនាំបច្ចេកទេស សម្រាប់ការអនុវត្តប្រព័ន្ធធានាសុវត្ថិភាពរេដជាតិ ដោយរួមបញ្ចូលទាំងការត្រួតពិនិត្យ និងការរាយការណ៍
- គ្រោងឡើងនូវដំណើរការប្រឹក្សាយោបល់ ពាក់ព័ន្ធនឹងសមាធាតុនានា ដោយផ្អែកលើយន្តការប្រឹក្សាយោបល់រេដ ដែលមានស្រាប់នៅកម្ពុជា ដោយធានាឲ្យបាននូវការចូលរួមយ៉ាងទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធ
- ផ្អែកតាមមតិយោបល់ដែលទទួលបានពីដំណើរការប្រឹក្សាយោបល់ ដាក់ជូនក្រុមការងាររេដ+កម្ពុជា នូវសំណើប្រព័ន្ធធានាសុវត្ថិភាពរេដជាតិ និងវិធាននានាដើម្បីធានាពហុប្រយោជន៍ ដោយរួមបញ្ចូលទាំងប្រព័ន្ធផ្តល់ព័ត៌មានថាតើប្រព័ន្ធធានាសុវត្ថិភាពរេដ ដោះស្រាយដោយរបៀបណា និងថាតើប្រព័ន្ធធានាសុវត្ថិភាពរេដ គោរពតាមគោលការណ៍ណែនាំ ដែលបានព្រមព្រៀង នៅក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដែរឬទេ។

*ភារកិច្ចជាក់លាក់របស់ក្រុមបច្ចេកទេស៖*

- ការចូលរួមប្រជុំប្រចាំខែ
- ការពិនិត្យឯកសារ និងបទបង្ហាញនានា និងផ្តល់យោបល់ កែលម្អលើឯកសារ និងបទបង្ហាញទាំងនោះ
- ផ្តល់ការណែនាំ និងជំនួយដល់ទីប្រឹក្សា និងបុគ្គលិកលេខាធិការដ្ឋានក្នុងការសិក្សា និងការព្រាងសំណើ
- ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។

ដោយសារមានកិច្ចការងារជាច្រើនដែលត្រូវបំពេញ ក្រុមបច្ចេកទេសត្រូវបង្កើតផែនការការងារ និងមានកំណត់ទំហំការងារជាក់លាក់ដែលត្រូវសម្រេចឲ្យបាន ដោយមានការពិភាក្សាជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីចាត់អាទិភាពការងារ។

## ៧. ការធ្វើរបាយការណ៍

សមាជិកក្រុមការងារបច្ចេកទេសនេះ ត្រូវទទួលខុសត្រូវធ្វើរបាយការណ៍ និងប្រឹក្សាយោបល់ជាមួយស្ថាប័នសាមី និងក្រុមគោលដៅរបស់ខ្លួន។ សមាជិកទាំងនេះអាចស្នើសុំឲ្យមានការផ្តល់ពេលវេលាជាបន្ថែមដើម្បីពិចារណាបញ្ហាជាក់លាក់នានា ប្រសិនបើយល់ថា បញ្ហាទាំងនោះមានសារៈសំខាន់ជាពិសេស ចំពោះស្ថាប័នរបស់ខ្លួន និងតម្រូវឲ្យមានការពិភាក្សាជាបន្ថែម។

ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដ+ ត្រូវធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់ទៅលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា តាមរយៈលេខាធិការ ក្រុមបច្ចេកទេសនេះ។

## ៨. រយៈពេល និងថេរវេលា

សមាជិកត្រូវធ្វើការរវាង ៣ ទៅ ៥ ថ្ងៃក្នុងមួយខែ អាស្រ័យលើសកម្មភាពដែលត្រូវអនុវត្ត។ ល័ក្ខខ័ណ្ឌប្រតិបត្តិនេះអាចនឹងកែសម្រួលនៅ ខែឧសភា ឆ្នាំ២០១៥។

## ៩. ថវិកាគាំទ្រ

ការគាំទ្រថវិកា នឹងផ្តល់ដោយ កម្មវិធី UN-REDD និង គម្រោង FCPF (R-PP) ដោយយោងទៅតាមថវិកាដែលបានអនុម័តសម្រាប់ការចំណាយ នៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចការនានាដែលទាក់ទងនឹងតួនាទីទាំងនេះ។ ការគាំទ្រមកពីក្របខ័ណ្ឌការងារផ្សេងទៀតនឹងត្រូវពិចារណាផងដែរ៕

***

# ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូរេដ+

( REDD+ Demonstration Technical Team )

(រេដ+៖ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ)

## លក្ខខ័ណ្ឌការងារ

## ១. សាវតា

យន្តការអនាគតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ(រេដ+) ដែលកំពុងរៀបចំតាមរយៈអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្តល់ឱកាសដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយកម្រិតនៃការរិចរឹលព្រៃឈើ និងជួយថែរក្សាការពារព្រៃធម្មជាតិ ក៏ដូចជាការបង្កើតព្រៃថ្មី។

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញនូវការគាំទ្រក្នុងការបង្កើតឲ្យមានវិធីសាស្ត្រសម្រាប់អនុវត្ត រេដ+ ដោយបានអនុម័តឲ្យមានគម្រោងសាកល្បងចំនួន២នៅឆ្នាំ២០០៨ និងឆ្នាំ២០០៩។ បន្ទាប់ពីនេះ មានគម្រោងសាកល្បងជាច្រើន បានចាប់ផ្តើមបង្កើត និងអនុវត្ត ដែលមានវឌ្ឍនភាពស្ថិតក្នុងដំណាក់កាលខុសៗគ្នា។ នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំដំណើរការផែនការត្រៀមលក្ខណៈសម្រាប់ រេដ+ ដែលនាំទៅដល់ ការបង្កើតសំណើផែនការត្រៀមលក្ខណៈសម្រាប់ រេដ+នៅកម្ពុជា (ផែនទីបង្ហាញផ្លូវ)។ ឯកសារនេះបង្ហាញថាតើកម្ពុជានឹងបង្កើត គោលនយោបាយ និងវិធានការអ្វីខ្លះដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់ រេដ+។

យោងតាមគោលបំណងរបស់ UNFCCC, ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ(រេដ+) គឺជាការអនុវត្តនៅកម្រិតជាតិ ប៉ុន្តែព្រមពេលជាមួយគ្នានេះ ក៏អនុញ្ញាតឲ្យមានការអនុវត្ត រេដ+ ផងដែរ នៅកម្រិតថ្នាក់ក្រោមជាតិ ទៅតាមវិធានការបណ្តោះអាសន្ន និងរីកចម្រើនឈានដល់ការអនុវត្តនៅកម្រិតជាតិ។ ស្របពេលជាមួយគ្នានេះ បទដ្ឋានកាបូនជាច្រើនដែលហៅថាទីផ្សារកាបូនស្ម័គ្រចិត្ត បានគ្រប់គ្រង និងប្រើជារបៀបសម្រាប់អនុវត្តនៅថ្នាក់គម្រោង។ វិធីសាស្ត្រទាំងបីបែបនេះ មានការលំបាក និងឱកាសផ្សេងៗគ្នា ដែលតម្រូវឲ្យបណ្តាប្រទេសនីមួយៗ ត្រូវវិភាគ ថ្លឹងថ្លែងពិចារណា ដោយផ្អែកលើកាលៈទេសៈ និងសមត្ថភាព ដើម្បីសម្រេចជ្រើសរើសយកវិធីសាស្ត្រណាមួយដែលប្រសើបំផុត។

ដោយរួមបញ្ចូលការអនុវត្តនៅកម្រិតជាតិ និងកម្រិតថ្នាក់ក្រោមជាតិ ត្រូវបានស្នើឡើងនៅក្នុងការចរចារជាអន្តរជាតិ ថាជាមធ្យោបាយក្នុងការប្រចាប់បញ្ចូលសកម្មភាពនៅថ្នាក់ក្រោមជាតិ ទៅក្នុងក្របខ័ណ្ឌគណនីជាតិ តាមរយៈ"វិធីសាស្ត្រសំបុកសត្វ" ("nested approach")។ ក្នុងគោលបំណងធ្វើឲ្យបានប្រសើបំផុត វិធីសាស្ត្រនេះនឹងរួមបញ្ចូលឲ្យមានអន្តរកាលនៅក្នុងគណនីរបស់ជាតិ ដែលនៅក្នុងពេលនេះអនុញ្ញាតឲ្យមានឥណទានសម្រាប់សកម្មភាពគម្រោងជាលក្ខណៈបុគ្គល ដែលជាវិធីសាស្ត្រកណ្តាល ដើម្បីជៀសវាងការថយចុះ។ ជាមួយគ្នានេះ បទដ្ឋានកាបូនទីផ្សារស្ម័គ្រចិត្ត ក៏នឹងបង្កើតវិធីសាស្ត្រសំបុកសត្វផងដែរ សម្រាប់គម្រោងជាលក្ខណៈបុគ្គល នៅក្នុងគណនី ថ្នាក់ក្រោមជាតិ(តាមដែនយុត្តាធិការ)។ តារាងដែលបានពីការសិក្សាឯកសារ បង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធ១។

បញ្ហាកាន់តែស្មុគ្រស្មាញបន្ថែមទៀតនោះ ប្រទេសនានាត្រូវសម្រេចពីកំរិតនៃការអនុវត្ត ដោយមិនផ្តល់ព័ត៌មានពីអ្វីដែលត្រូវទាមទារក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តរេដ+ នាពេលអនាគត ដោយសារតែនាពេលបច្ចុប្បន្ន ការចរចារអំពីរេដ+ កំពុងតែបន្ត និងស្របពេលជាមួយគ្នានេះ ទីផ្សារកាបូនស្ម័គ្រចិត្តនៅថ្នាក់តំបន់កំពុងអភិវឌ្ឍន៍។ ភាពមិនច្បាស់លាស់ និងគោលការណ៍ណែនាំដែលមានស្រាប់របស់ UNFCCC ស្តីពីការអនុវត្តនៅកម្រិតថ្នាក់ក្រោមជាតិ បានបញ្ជាក់ពីសារសំខាន់នៃការបង្កើតប្រព័ន្ធមួយ ដែលមានភាពទន់ភ្លន់សម្រាប់វាស់វែងការបូន និងកំណត់កំរិតយោង ក្នុងទម្រង់ដែលអនុញ្ញាតឲ្យមានទំនាក់ទំនងនឹងការត្រួតពិនិត្យ និងការរាយការណ៍នៅថ្នាក់ជាតិ ដោយមិនគិតពីកំរិតនៃការអនុវត្តមានការចូលចិត្តឡើយ។

ប្រសិនបើ រេដ+ នៅកម្ពុជា មានការរីវឌ្ឍន៍ប្រកបដោយភាពស័ក្តិសិទ្ធិ និងមានប្រសិទ្ធិភាព ជាការសំខាន់ណាស់ដែលព័ត៌មាន និងមេរៀនជាបទពិសោធន៍ ដែលបានមកពីគម្រោងសាកល្បង ក៏ដូចជាព័ត៌មានស្តីពីការអនុវត្ត រេដ+ តាមទម្រង់ផ្សេងៗនៅក្នុងប្រទេសនានា ត្រូវបានចែករំលែក និងវិភាគ ដើម្បីជួយដល់ការសម្រេចចិត្ត ថាតើ រេដ+ នៅកម្ពុជាត្រូវអនុវត្តដោយរបៀបណា ។

## ២. គោលបំណង

គោលបំណងរបស់ក្រុមការងារបច្ចេកទេសស្តីពីការអនុវត្តគម្រោងគំរូ គឺជានាថាមេរៀន និងបទពិសោធន៍ ដែលបានមកពីការអនុវត្តគម្រោងគំរូ ត្រូវបានកត់ត្រា និងវិភាគ ដើម្បីគាំទ្រដល់ការបង្កើតវិធីសាស្រ្ត សម្រាប់អនុវត្តនៅថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃកម្មវិធីរេដ+ថ្នាក់ជាតិ។ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ ត្រូវគាំទ្រដល់ការបង្កើតគោលការណ៍ណែនាំ សម្រាប់វិធីសាស្រ្តអនុវត្តនៅថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃវិធីសាស្រ្តសំបុកសត្វ នៅក្នុងក្របខ័ណ្ឌការងារថ្នាក់ជាតិ ដោយរួមបញ្ចូលទាំងអនុសាសន៍សម្រាប់អនុវត្តគម្រោងគំរូផងដែរ ។

## ៣. សមាជិកភាព

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូមានសមាជិកមកពី៖

- ក្រសួងមហាផ្ទៃ ចំនួន១នាក់(អគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន)
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន១នាក់(អគ្គនាយកដ្ឋាន ថាមពល)
- ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន១នាក់
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន១នាក់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ១នាក់,
- ការិយាល័យពាក់ព័ន្ធ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ១នាក់
- ការិយាល័យពាក់ព័ន្ធ រដ្ឋបាលជលផល១នាក់
- សមាជិកក្រុមប្រឹក្សាយោបល់ រេដ+ កម្ពុជា ចំនួន៣នាក់ ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ (ក្រុមប្រឹក្សាយោបល់នឹងចាត់តាំងសមាជិកក្រុមមកចូលរួម)
- លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ចំនួន២នាក់ នឹងត្រូវចាត់តាំងដោយ ប្រធានលេខាធិការដ្ឋាន។

សមាជិកទាំងអស់ត្រូវចាត់តាំងតំណាងមកចូលរួមជំនួសក្នុងកិច្ចប្រជុំនានា ប្រសិនបើមានធុរៈចាំបាច់។ យោងតាមតម្រូវការជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ នឹងអាចអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំ។

## ៤. ប្រតិបត្តិការ

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូរេដ+ត្រូវជួបប្រជុំប្រចាំខែ។ ប្រធានក្រុមការងារបច្ចេកទេស នឹងត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុម និងអនុម័តដោយប្រធានលេខាធិការដ្ឋាន។ ប្រធានក្រុមការងារបច្ចេកទេស ជាប្រធានដឹកនាំកិច្ចប្រជុំ។ សមាជិកដែលមកពីលេខាធិការដ្ឋានម្នាក់ នឹងត្រូវតែងតាំងជាលេខាធិការ របស់ក្រុមការងារបច្ចេកទេស ។ លេខាធិការក្រុមបច្ចេកទេសអនុវត្តគម្រោងគំរូរេដ+ ត្រូវជានាថាលិខិតអញ្ជើញចូលរួមកិច្ចប្រជុំដោយមានភ្ជាប់ឯកសារដែលត្រូវពិភាក្សា បានផ្ញើជូនដល់គ្រប់សមាជិក រយៈពេល១សប្តាហ៍មុនកិច្ចប្រជុំ។ លេខាធិការត្រូវធ្វើសេចក្តីព្រាងកំណត់ ហេតុកិច្ចប្រជុំ ជូនគ្រប់សមាជិកក្នុងរយៈពេល៣ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំ។ សមាជិកទាំងអស់ត្រូវផ្តល់យោបល់លើសេចក្តីព្រាងកំណត់ហេតុ កិច្ចប្រជុំក្នុងរយៈពេល៣ថ្ងៃ បន្ទាប់មកលេខាធិការកែសម្រួលកំណត់ហេតុកិច្ចប្រជុំតាមការផ្តល់យោបល់ និងផ្ញើកំណត់ហេតុសម្រេចជូនគ្រប់សមាជិកក្រុមបច្ចេកទេស។ កំណត់ហេតុកិច្ចប្រជុំត្រូវមាន កាលបរិច្ឆេទ ពេលវេលា ទីកន្លែង ប្រធានបទជាបន្តបន្ទាប់ក្នុងកិច្ចប្រជុំ និងផ្សព្វផ្សាយជាសាធារណៈ ជូនដល់គ្រប់អ្នកពាក់ព័ន្ធ តាមរយៈក្រុមប្រឹក្សាយោបល់ និងដាក់នៅក្នុងគេហទំព័រ រេដ+កម្ពុជា។ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូរេដ+ នឹងមានការជួយគាំទ្របច្ចេកទេស ពីអ្នកឯកទេសអន្តរជាតិ និងទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិផងដែរ។

## ៥. ការធ្វើសេចក្ដីសម្រេច

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូនេះមិនមែនជាអ្នកធ្វើសេចក្ដីសម្រេចទេ ប៉ុន្តែជាអ្នកផ្ដល់អនុសាសន៍ដល់ក្រុមការងារ រេដ+ កម្ពុជា និង លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ជារៀងរាល់ខែ។ អនុសាសន៍នានានឹងត្រូវធ្វើឡើង តាមគោលការណ៍នៃការឯកភាពមតិ។

## ៦. ការទទួលខុសត្រូវ

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូនេះ ត្រូវធ្វើការជាមួយលេខាធិការដ្ឋានក្រុមការងាររេដ+កម្ពុជា ដើម្បីគាំទ្រដល់ការបង្កើតគោលការណ៍ណែនាំ និងវិធីសាស្ត្រ សម្រាប់ការអនុវត្តគម្រោងគំរូនៅថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំងការជ្រើសរើសតំបន់សម្រាប់ការអនុវត្តគម្រោងគំរូផងដែរ។ ការបង្កើតគោលការណ៍ណែនាំ និងវិធីសាស្ត្រ នេះត្រូវផ្អែកលើមូលដ្ឋាននៃមេរៀន និងបទពិសោធន៍ ដែលដកស្រង់ចេញពីការអនុវត្តគម្រោងគំរូដែលមានស្រាប់។ ការងារបច្ចេកទេសរួមមាន៖

- អនុវត្តដោយផ្ទាល់ ឬ ចាត់ចែងឲ្យមានការសិក្សា ពីការអនុវត្តគម្រោងគំរូនៅក្នុង និងក្រៅប្រទេស និងវិធីសាស្ត្រអនុវត្ត នៅថ្នាក់ក្រោមជាតិ
- សម្របសម្រួលជាមួយដៃគូដែលធ្វើការងារក្នុងវិស័យដូចគ្នា
- បង្កើតអនុសាសន៍សម្រាប់សកម្មភាពអនុវត្តគម្រោងគំរូរេដ+
- អនុវត្តដោយផ្ទាល់ ឬ ចាត់ចែងឲ្យមានការសិក្សា ពីបទពិសោធន៍ដែលមានស្រាប់សម្រាប់ការចុះបញ្ជី
- បង្កើតអនុសាសន៍សម្រាប់បែបបទនៃការចុះបញ្ជី រេដ+ នៅថ្នាក់ជាតិ
- ប្រឹក្សាយោបល់ជាមួយក្រុមបច្ចេកទេសដទៃទៀតនៅពេលដែលមានការពាក់ព័ន្ធ

ដើម្បីជៀសវាងបញ្ហាអនុវត្តការងារត្រួតលើគ្នា ជាការចាំបាច់ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ ត្រូវធ្វើការ និងសម្របសម្រួលជាមួយ ក្រុមបច្ចេកទេសបីដទៃទៀត ដែលកំពុងដឹកនាំ និងបំពេញការងារលើ៖ ១)ការចែករំលែកផលប្រយោជន៍ ២)ប្រព័ន្ធធានាសុវត្ថិភាព និង ៣) ត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់កំរិតយោង នៅថ្នាក់ជាតិ ។ ភារកិច្ចជាក់លាក់របស់ក្រុមនេះត្រូវពិចារណាថាតើ សមាសភាគទាំងអស់អាចអនុវត្តវិធីសាស្ត្រដោយរបៀបណានៅថ្នាក់ក្រោមជាតិ និងបន្ទាប់មកវិធីសាស្ត្រអនុវត្តនៅថ្នាក់ជាតិ។

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូនឹងផ្ដល់អនុសាសន៍ដល់ក្រុមការងារ រេដ+ កម្ពុជាតាមរយៈ

- ពិនិត្យរបាយការណ៍គម្រោងសាកល្បង រេដ+ និងឯកសារផ្សេងៗ
- ពិភាក្សាជាមួយអ្នកគ្រប់គ្រងគម្រោង និងអ្នកពាក់ព័ន្ធនឹងការគាំទ្រកម្មវិធី រេដ+
- ចុះពិនិត្យដល់ទីវាលប្រសិនបើមានការចាំបាច់

*ភារកិច្ចជាក់លាក់របស់ក្រុមបច្ចេកទេស៖*

- ការចូលរួមប្រជុំប្រចាំខែ
- ការពិនិត្យឯកសារ និងបទបង្ហាញនានា និងផ្ដល់យោបល់ កែលម្អលើឯកសារ និងបទបង្ហាញទាំងនោះ
- ផ្ដល់ជាជំនួយដល់ទីប្រឹក្សា និងបុគ្គលិក លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ក្នុងការអនុវត្តកិច្ចការរបស់ពួកគេ
- ចូលរួមនៅក្នុងវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលានានា។

ដោយសារមានកិច្ចការងារជាច្រើនដែលត្រូវបំពេញ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូត្រូវបង្កើតផែនការការងារ និងមានកំណត់ទំហំការងារ ជាក់លាក់ដែលត្រូវសម្រេចឲ្យបាន ដោយមានការពិភាក្សាជាមួយលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ដើម្បីចាត់អាទិភាពការងារ។

## ៧. ការធ្វើរបាយការណ៍

សមាជិកក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូនេះ ត្រូវទទួលខុសត្រូវធ្វើរបាយការណ៍និងប្រឹក្សាយោបល់ជាមួយស្ថាប័នសាមី និងក្រុមគោលដៅរបស់ខ្លួន។ សមាជិកទាំងនេះអាចស្នើសុំឲ្យមានការផ្ដល់ពេលវេលាជាបន្ថែមដើម្បីពិចារណាបញ្ហាជាក់លាក់នានា ប្រសិនបើយល់ថា បញ្ហាទាំងនោះមានសារៈសំខាន់ជាពិសេស ចំពោះស្ថាប័នរបស់ខ្លួន និងតម្រូវឲ្យមានការពិភាក្សាជាបន្ថែម។

ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ ត្រូវធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់ទៅលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា តាមរយៈលេខាធិការ ក្រុមបច្ចេកទេសនេះ។

## ៨. រយៈពេល និងថេរវេលា

សមាជិកត្រូវធ្វើការប្រមាណជា១ថ្ងៃ ទៅ ៣ថ្ងៃ ក្នុងមួយខែ អាស្រ័យលើសកម្មភាពដែលត្រូវអនុវត្ត។ លក្ខខ័ណ្ឌប្រតិបត្តិនេះ អាចនឹងកែសម្រួលបានទៅតាមការស្នើសុំរបស់ក្រុមការងារបច្ចេកទេស ដោយមានការអនុម័តពីក្រុមការងារ រេដ+ កម្ពុជា។

## ៩. ថវិកាគាំទ្រ

ការគាំទ្រថវិកា នឹងផ្តល់ដោយ កម្មវិធី UN-REDD និង គម្រោង FCPF (R-PP) ដោយយោងទៅតាមថវិកាដែលបានអនុម័ត សម្រាប់ការចំណាយ នៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចការនានាដែលទាក់ទងនឹងតួនាទីទាំងនេះ។ ការគាំទ្រមកពីក្របខ័ណ្ឌការងារផ្សេងទៀតនឹងត្រូវពិចារណាផងដែរ៕

***

# ក្រុមការងារបច្ចេកទេសត្រួតពិនិត្យរាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន

(REDD+ MRV/REL Technical Team)

(រេដ+៖ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ)

## លក្ខខ័ណ្ឌការងារ

## ១. សាវតា

យន្តការអនាគតសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ(រេដ+) ដែលកំពុងរៀបចំតាមរយៈអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងផ្តល់ឱកាសដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីកាត់បន្ថយកម្រិតនៃការរិចរឹលព្រៃឈើ និងជួយថែរក្សាការពារព្រៃធម្មជាតិ ក៏ដូចជាការបង្កើតព្រៃថ្មី។ សកម្មភាពចំនួន៥បានចុះបញ្ជីស្ថិតក្រោមយន្តការរេដ+(សន្និសិទ្ធលើកទី១៦ របស់បណ្តាភាគី សេចក្តីសម្រេចទី១ កថាខ័ណ្ឌទី៧០) រួមមាន៖ ១)ការកាត់បន្ថយការបញ្ចេញឧស្ម័នបណ្តាលមកពីការការបាត់បង់ព្រៃឈើ ២)ការកាត់បន្ថយការបញ្ចេញឧស្ម័នបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ ៣)ការអភិរក្សព្រៃកាបូនស្តុក ៤)ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ៥)ការពង្រឹងនិងពង្រីកព្រៃឈើកាបូនស្តុក។

នៅឆ្នាំ២០១០ ដោយមានការគាំទ្រពី កម្មវីធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) និងអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(FAO)ប្រចាំកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំដំណើរការផែនការត្រៀមលក្ខណៈសម្រាប់ រេដ+ ដែលនាំទៅដល់ ការបង្កើតសំណើផែនការត្រៀមលក្ខណៈសម្រាប់ រេដ+នៅកម្ពុជា (ផែនទីបង្ហាញផ្លូវ)។ ឯកសារនេះបង្ហាញថាតើកម្ពុជា នឹងបង្កើតគោលនយោបាយ និងវិធានការអ្វីខ្លះដើម្បីត្រៀមលក្ខណៈជាស្រេចសម្រាប់ រេដ+។ សមាសភាគសំខាន់ដើម្បីត្រៀមលក្ខណៈ ជាស្រេចសម្រាប់ រេដ+ គឺត្រូវមានប្រព័ន្ធដ៏មានតម្លាភាពនៅនឹងកន្លែង និងមានវិធាននិងវិធីសាស្ត្រច្បាស់លាស់ សម្រាប់ការត្រួតពិនិត្យ និងចែករំលែកព័ត៌មាន។ ប្រព័ន្ធនេះត្រូវមានមុខងារពីរ ដើម្បីត្រួតពិនិត្យសកម្មភាព រេដ+ ១)មុខងារត្រួតពិនិត្យ ២)មុខងារវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់។

**១)មុខងារត្រួតពិនិត្យ៖** ប្រព័ន្ធត្រួតពិនិត្យ រេដ+ ទាមទារឲ្យមានការប៉ាន់ប្រមាណតំបន់ព្រៃឈើ ដែលមានការប្រែប្រួលតាមពេលវេលា ដើម្បីប៉ាន់ប្រមាណថាតើ រេដ+ ទទួលបានលទ្ធផលជាវិជ្ជមានឬយ៉ាងណា? កម្ពុជាអាចប្រើប្រាស់ប្រព័ន្ធក្នុងស្រុក ដើម្បីវាយតម្លៃគោលនយោបាយស្តារព្រៃឈើឡើងវិញ។

**២)មុខងារវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់៖** សម្រាប់ រេដ+ ដើម្បីវាស់វែង ការបញ្ចេញ ឬ ការស្រូបយកឧស្ម័នដោយព្រៃឈើ និងការប្រែប្រួលការប្រើប្រាស់ដី ក៏ដូចជាការរាយការណ៍ពីការបញ្ចេញឧស្ម័ន (ឬការកាត់បន្ថយដោយសារសកម្មភាព រ៉េដ+) ជូន UNFCCC ដើម្បីធ្វើសារពើភ័ណ្ឌពីការបញ្ចេញឧស្ម័ន និងពិនិត្យផ្ទៀងផ្ទាត់។ ដើម្បីឲ្យប្រព័ន្ធផ្អែកលើមូលដ្ឋាននៃលទ្ធផល ការបញ្ចេញ និង ការស្រូបយកឧស្ម័នដោយព្រៃឈើ និងការប្រែប្រួលការប្រើប្រាស់ដី ស្ថិតក្រោមសកម្មភាពទាំង៥របស់ រ៉េដ+ គឺត្រូវធ្វើការប្រៀបធៀបជាមួយនិងទិន្នន័យដើម គឺកំរិតយោងនៃព្រៃឈើ (Forest Reference Levels) ឬ កំរិតយោងនៃការបញ្ចេញឧស្ម័ន (Reference Emission Levels)។

## ២. គោលបំណង

គោលបំណងរបស់ក្រុមការងារបច្ចេកទេសត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន (MRV/REL Technical Team) គឺជានាថាសមត្ថភាព បច្ចេកទេសពាក់ព័ន្ធនឹង រេដ+ បានផ្តល់ជូនស្ថាប័នក្រុមការងាររេដ+ លេខាធិការដ្ឋានរេដ+ និង

សមាសភាគសំខាន់ៗរបស់រេដ+ ដើម្បីបំពេញមុខងារ ប្រកបដោយតម្លាភាព សង្គហាតិភាព ត្រួតពិនិត្យដោយគ្មានលំអៀង និងមានប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន ។

## ៣. ការទទួលខុសត្រូវ

ការទទួលខុសត្រូវជាក់លាក់របស់ក្រុមបច្ចេកទេសត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន (MRV/REL Technical Team) គឺ ៖

- បង្កើតចំណាត់ថ្នាក់ព្រៃឈើជាតិ
- បង្កើតប្រព័ន្ធមួយសម្រាប់កម្ពុជា ដែលបំពេញមុខងារ ត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោង រេដនៅកម្ពុជា
- បង្កើតប្រព័ន្ធវាយតម្លៃគម្របព្រៃឈើជាតិ ដោយផ្កាយរណប (design the satellite forest monitoring system) ដើម្បីជួយគាំទ្រដល់ការបង្កើតទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពព្រៃឈើ ឲ្យស្របតាមការទាមទារសំណាកគំរូរបស់សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់
- បង្កើតគំរូសារពើភ័ណ្ឌព្រៃឈើជាតិ ដើម្បីបង្កើតជាកត្តាសម្រាប់គណនាសកម្មភាពនានាដែលពាក់ព័ន្ធនឹងការបញ្ចេញ និងការស្រូបឧស្ម័ន ដែលបណ្តាលមកពីការការបាត់បង់ និងរិចរឹលព្រៃឈើ
- បង្កើតរយៈពេលយោង (reference period)
- បង្កើតកំរិតយោងថ្នាក់ជាតិ (National reference levels)
- បង្កើតកំរិតយោងក្របខ័ណ្ឌការងារ សម្រាប់គណនីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើតហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស ដើម្បីរៀបចំអនុវត្តប្រព័ន្ធវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ព្រៃឈើ
- កំណត់ស្ថាប័នទទួលខុសត្រូវក្នុងការត្រួតពិនិត្យ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ការកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលបណ្តាល មកពីការការបាត់បង់ និងរិចរឹលព្រៃឈើ
- រក្សាទិន្នន័យដើមសម្រាប់ការត្រួតពិនិត្យ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ព្រៃឈើ
- សម្របសម្រួលដល់ការប្រើប្រាស់ និងចែកចាយទិន្នន័យដល់អ្នកពាក់ព័ន្ធ ត្រួតពិនិត្យ QC/QA និងផ្ទៀងផ្ទាត់។
- រៀបចំការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់(GHG) ជាបណ្តោះអាសន្ន ដែលពាក់ព័ន្ធនិង ការប្រើប្រាស់ដី ការផ្លាស់ប្តូរ ការប្រើប្រាស់ដី និងព្រៃឈើ (LULUCF) ។
- បង្កើតផែនការអនុវត្តប្រចាំត្រីមាស និងប្រចាំឆ្នាំ និងកែសម្រួលផែនការ សម្រាប់ការគ្រប់គ្រងទិន្នន័យ
- បំពេញកាតព្វកិច្ចដទៃទៀតដែលពាក់ព័ន្ធនឹងការបង្កើត និងការអភិវឌ្ឍន៍ប្រព័ន្ធ ត្រួតពិនិត្យ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាល មកពីការការបាត់បង់ និងរិចរឹលព្រៃឈើ។

ភារកិច្ចនិងការទទួលខុសត្រូវជាក់លាក់របស់សមាជិកនីមួយៗរួមមាន:

- ចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ
- ពិនិត្យឯកសារ ធ្វើបទបង្ហាញ និងផ្តល់យោបល់ លើឯកសារទាំងនោះ
- ផ្តល់ការណែនាំ និងផ្តល់ជំនួយដល់ទីប្រឹក្សា និងផ្តល់ការគាំទ្រដល់មន្ត្រីលេខាធិការដ្ឋានក្នុងការបំពេញការងារ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា

## ៤. សមាជិកភាព

ក្រុមការងារបច្ចេកទេសត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន មានសមាជិកមកពី៖

- ការិយាល័យពាក់ព័ន្ធ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន១នាក់(អគ្គនាយកដ្ឋាន ថាមពល)

- សមាជិកក្រុមប្រឹក្សាយោបល់ រេដ+ កម្ពុជា ចំនួន៥នាក់ ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ ចាត់តាំងដោយក្រុមប្រឹក្សាយោបល់ និងអនុម័តដោយប្រធានលេខាធិការដ្ឋាន
- លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ចំនួន២នាក់ នឹងត្រូវចាត់តាំងដោយ ប្រធានលេខាធិការដ្ឋាន
- ប្រសិនបើមានការចាំបាច់ ប្រធានក្រុមការងារបច្ចេកទេសនេះ អាចស្នើសុំសមាជិកបន្ថែមមកចូលរួម។

សមាជិកទាំងអស់ត្រូវចាត់តាំងតំណាងមកចូលរួមជំនួសក្នុងកិច្ចប្រជុំនានា ប្រសិនបើមានធុរៈចាំបាច់។ តំណាងបន្ថែមរួមមានអ្នកពាក់ព័ន្ធមកពីអង្គការមិនមែនរដ្ឋាភិបាល អាចអញ្ជើញចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

## ៥. ប្រតិបត្តិការ

ដោយសារមានការងារច្រើន ក្រុមបច្ចេកទេសនេះត្រូវរៀបចំផែនការការងារ ដែលមានគោលដៅច្បាស់លាស់ ដោយមានការប្រឹក្សាយោបល់ជាមួយលេខាធិការដ្ឋាន និងព្រមព្រៀងលើការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗ ក្នុងការគាំទ្រលើផ្នែកបច្ចេកទេសជាក់លាក់ និងផ្តល់ប្រឹក្សាលើការងារ ដើម្បីចាត់អាទិភាពឲ្យមានប្រសិទ្ធិភាពការងារ។ ក្រុមបច្ចេកទេសនេះត្រូវជួបប្រជុំប្រចាំខែ។ លេខាធិការក្រុមបច្ចេកទេស ត្រូវជានាថាលិខិតអញ្ជើញចូលរួមកិច្ចប្រជុំដោយមានភ្ជាប់ឯកសារដែលត្រូវពិភាក្សា បានផ្ញើជូនដល់គ្រប់សមាជិកមុនកិច្ចប្រជុំ។ លេខាធិការត្រូវធ្វើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំ ជូនគ្រប់សមាជិកក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ។ សមាជិកទាំងអស់ត្រូវផ្តល់យោបល់លើសេចក្តីព្រាងកំណត់ហេតុ កិច្ចប្រជុំក្នុងរយៈពេល៣ថ្ងៃ បន្ទាប់មកលេខាធិការ កែសម្រួលកំណត់ហេតុកិច្ចប្រជុំតាមការផ្តល់យោបល់ និងធ្វើកំណត់ហេតុសម្រេចជូនគ្រប់សមាជិកក្រុមបច្ចេកទេស។ ក្រុមការងារបច្ចេកទេស នឹងមានការជួយគាំទ្របច្ចេកទេស ពីអ្នកឯកទេសអន្តរជាតិ និងទីប្រឹក្សាបច្ចេកទេសអន្តរជាតិផងដែរ។

## ៦. ការធ្វើសេចក្តីសម្រេច

ក្រុមបច្ចេកទេសនេះមិនមែនជាអ្នកធ្វើសេចក្តីសម្រេចទេ ប៉ុន្តែជាអ្នកផ្តល់អនុសាសន៍ដល់ក្រុមការងារ រេដ+ កម្ពុជា និងលេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជា ជារៀងរាល់ខែ។ អនុសាសន៍នានានឹងត្រូវធ្វើឡើង តាមគោលការណ៍នៃការឯកភាពមតិ។

## ៧. ការធ្វើរបាយការណ៍

សមាជិកក្រុមបច្ចេកទេសនេះ ត្រូវទទួលខុសត្រូវធ្វើរបាយការណ៍ និងប្រឹក្សាយោបល់ជាមួយស្ថាប័នសាមី និងក្រុមគោលដៅរបស់ខ្លួន។ លេខាធិការដ្ឋានក្រុមការងារ រេដ+ កម្ពុជាទទួលខុសត្រូវធ្វើរបាយការណ៍ក្រុមការងារ រេដ+ កម្ពុជា ដែលជាថ្នាក់គ្រប់គ្រងរបស់ខ្លួន។

## ៨. រយៈពេល និងថេរវេលា

សមាជិកត្រូវធ្វើការប្រមាណ ១ថ្ងៃ ទៅ ៣ថ្ងៃ ក្នុងមួយខែ អាស្រ័យលើសកម្មភាពដែលត្រូវអនុវត្ត។

## ៩. ថវិកាគាំទ្រ

ការគាំទ្រថវិកា នឹងផ្តល់ដោយ កម្មវិធី UN-REDD និង គម្រោង FCPF (R-PP) ដោយយោងទៅតាមថវិកាដែលបានអនុម័តសម្រាប់ការចំណាយ នៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចការនានាដែលទាក់ទងនឹងតួនាទីទាំងនេះ។ ការគាំទ្រមកពីក្របខ័ណ្ឌការងារផ្សេងទៀតនឹងត្រូវពិចារណាផងដែរ៕

***

# កម្មវិធីទស្សនកិច្ចសិក្សា
# សម្រាប់ក្រុមការងាររេដបូកកម្ពុជា

ថ្ងៃទី០៦ ដល់ ១១ ខែតុលា ឆ្នាំ២០១៣

គោលបំណងទស្សនកិច្ចសិក្សា៖ ស្វែងយល់ពីមេរៀន និងបទសោធន៍ដំណាក់កាលត្រៀមសម្រាប់រេដបូក នៅប្រទេស វៀតណាម

| កាលបរិច្ឆេទ | សកម្មភាព | ផ្សេងៗ |
|---|---|---|
| ០៦ តុលា ២០១៣៖ | | |
| 18:30 | ការអញ្ជើញដល់ទីក្រុងហាណូយនៃគណៈប្រតិភូ (VN 3866) | |
| ០៧ តុលា ២០១៣៖ | | |
| ពេលព្រឹក | កិច្ចស្វាគមន៍របស់ VNFOREST និងRECOFTC និងការណែនាំស្វែងយល់ពីដំណើរទៅទៅរេដបូកនៅវៀតណាម | |
| ពេលរសៀល | ពិភាក្សាតុមូលលើប្រធានបទដែលពាក់ព័ន្ធនឹងការងារការរេដបូក (សេចក្តីផ្តើមពីរេដបូក ការកសាងសមត្ថភាព ការធានាសុវត្ថភាពរេដបូក ការបែងចែកផលប្រយោជន៍ ល។ល។) | |
| | ស្នាក់នៅទីក្រុងហាណូយ | |
| ០៨ តុលា ២០១៣៖ | | |
| ពេលព្រឹក | គណៈប្រតិភូធ្វើដំណើរទៅកាន់ខេត្ត Lam Dong (មកដល់ ម៉ោង ១២.៥០) | |
| ពេលរសៀល | កិច្ចស្វាគមន៍របស់គណៈកម្មធិការប្រជាជនខេត្ត Lam Dong ជួបជាមួយ ក្រុមការងារគម្រោង រេដបូក នៃអង្គការ SNV | |
| | ស្នាក់នៅ Da Lat ទីរួមខេត្ត Lam Dong | |
| ០៩ តុលា ២០១៣៖ | | |
| ពេលព្រឹក | ទស្សនកិច្ចទៅកាន់តំបន់គោលដៅ នៃ UNREDD ដំណាក់កាលទី១ | |

| | | |
|---|---|---|
| | (ស្រុក Lam Ha ឬ ស្រុក Di Linh) | |
| ពេលរសៀល | បន្តដំណើរទីកាន់ស្រុក Bao Loc | |
| | ស្នាក់នៅស្រុក Bao Loc នៃខេត្ត Lam Dong | |
| ១០ តុលា ២០១៣៖ | | |
| ពេលព្រឹក | ទស្សនកិច្ចទៅកាន់តំបន់គោលដៅគម្រោងនៃអង្គការ SNV នៅស្រុក Bao Loc | |
| ពេលរសៀល | ត្រឡប់មកកាន់ទីរួមខេត្តវិញ (Da Lat)<br>ឆ្លុះបញ្ចាំងពីលទ្ធផលនៃទស្សនកិច្ចសិក្សា | |
| | ស្នាក់នៅ Da Lat ទីរួមខេត្ត Lam Dong | |
| ១១ តុលា ២០១៣៖ | | |
| ពេលព្រឹក | គណៈប្រតិភូធ្វើដំណើរពី Da lat ទៅ Ho Chi Minh (VN 1381) | |
| ពេលរសៀល | គណៈប្រតិភូធ្វើដំណើរពីរ Ho Chi Minh មកភ្នំពេញ (VN 3855) | |

Annex 5

CAMBODIA REDD+

**កិច្ចប្រជុំលើកទី១ក្រុមការងារ REDD+ កម្ពុជា**

ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៣

សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

## រេដ+នៅថ្នាក់អន្តរជាតិ

បង្ហាញដោយ : លោក ភីធើរ អ៊ីវើសិន
អ្នកឯកទេសរេដប្រចាំលេខាធិការដ្ឋានREDD+កម្ពុជា
E-mail: peter.iversen@undp.org

## ការបំភាយឧស្ម័ននៅលើពិភពលោកបន្តកើនឡើង




CAMBODIA REDD+ PROGRAMME

## ពិភពលោកមានការបាត់បង់ព្រៃឈើប្រហែល ១៣លាន ហិកតា ជារៀងរាល់ឆ្នាំ



CAMBODIA REDD+ PROGRAMME

## ក្របខ័ណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តី អំពីការប្រែប្រួលអាកាសធាតុ



Annex 5

## REDD+






## កិច្ចព្រមព្រៀង ខេនឃូន( Cancun Agreements ) COP១៦ នៅឆ្នាំ២០១០

ការស្នើសុំឲ្យប្រទេសទាំងឡាយដើម្បីបង្កើតឡើង៖

យុទ្ធសាស្រ្តREDD+ថ្នាក់ជាតិ៖

- ប្រព័ន្ធអង្កេតថ្នាក់ជាតិ
- កម្រិតយោងនៃការបញ្ចេញឧស្ម័ន
- ប្រព័ន្ធកិច្ចការពារសុត្ថិភាព



## ស្ថានភាពបច្ចុប្បន្ននៃរេដ+

- បច្ចុប្បន្នមានជាង៥០ប្រទេសនៅជុំវិញពិភពលោក ចូលរួមនៅក្នុងការកិច្ចផ្តួចផ្តើមរេដផ្សេងៗគ្នា
- គោលបំណងការកាត់បន្ថយការបំភាយឧស្ម័នឲ្យបាន ៥០%នៅឆ្នាំ២០២០



## ការចរចាស្តីពី រេដ+ កំពុងបន្តនៅលើពិភពលោក

- តើមានតម្រូវការអ្វីខ្លះដើម្បីទទួលបានហិរញ្ញប្បទានរេដ?
- ការអនុវត្តត្រឹមកំរិតគម្រោងទំនងមិនទាន់គ្រប់គ្រាន់ទេ
- មិនប្រាកដថា កិច្ចព្រមព្រៀងស្តីពីការប្រែប្រួលអាកាសធាតុពិភពលោក ឆ្នាំ២០២០មានរួមបញ្ចូលរេដ?
- មានជម្រើសផ្សេងៗគ្នាក្នុងអំឡុងពេល ២០១៣– ២០២០

Annex 5

## Forests are more than carbon




CAMBODIA REDD+ PROGRAMME

## សូមអរគុណ

CAMBODIA REDD+ PROGRAMME

CAMBODIA REDD+

**កិច្ចប្រជុំលើកទី១ក្រុមការងារ REDD+ កម្ពុជា**

ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៣

សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

## វឌ្ឍនភាព REDD+ នៅកម្ពុជា

បង្ហាញដោយ : លោក ឃុន វឌ្ឍនា

ប្រធានលេខាធិការដ្ឋានREDD+កម្ពុជា

E-mail: vathana.khun@gmail.com

CAMBODIA REDD+

## មាតិកា

១ ការចូលរួមរបស់កម្ពុជានៅក្នុងដំណើការ REDD+

២ កម្មវិធីកំពុងគាំទ្រ REDD+ នៅកម្ពុជា

៣ វឌ្ឍនភាព REDD+ នៅកម្ពុជានាពេលបច្ចុប្បន្ន

CAMBODIA REDD+ PROGRAMME

Annex 5

## ១ ការចូលរួមរបស់កម្ពុជានៅក្នុងដំណើរការរេដ+

- ចូលជាសមាជិក មូលនិធិភាពជាដៃគូកាបូនព្រៃឈើ (FCPF) និង UN-REDD នៅឆ្នាំ២០០៩
- បានបង្កើតក្រុមការងារបណ្តោះអាសន្ន REDD+ កម្ពុជានៅឆ្នាំ២០១០
- បានបង្កើតផែនទីបង្ហាញផ្លូវរេដ+ (REDD+ Roadmap) នៅឆ្នាំ២០១០
- កម្មវិធី UN-REDD កម្ពុជាបានចុះហត្ថលេខានៅខែឧសភាឆ្នាំ២០១១
- បានបង្កើតក្រុមការងារ REDD+ កម្ពុជាជាផ្លូវការនៅឆ្នាំ២០១៣ និង លេខាធិការដ្ឋាន REDD+ កម្ពុជា

CAMBODIA REDD+ PROGRAMME

## ដំណើការត្រៀមលក្ខណៈសម្រាប់រេដនៅកម្ពុជា

- ជំហានទី ១ : សរសេរផែនទីបង្ហាញផ្លូវ 2010
- ជំហានទី ២ : អនុវត្តផែនទីបង្ហាញផ្លូវ 2011–2014
- ជំហានទី ៣ : ចូលរួមអនុវត្ត REDD+ ចាប់ពី 2015

CAMBODIA REDD+ PROGRAMME

## កម្មវិធីគាំទ្រការត្រៀមលក្ខណៈរេដនៅកម្ពុជា




CAMBODIA REDD+ PROGRAMME

## ❖ គោលបំណងនៃកម្មវិធី និងគម្រោង

- កម្មវិធី និងគម្រោង ខាងលើនេះ មាន គោលបំណង គាំទ្រដល់កម្ពុជា ដើម្បីត្រៀមលក្ខណៈ សម្រាប់ការអនុវត្តរេដ+ នៅកម្ពុជា ដែលការគាំទ្រនេះផ្តោតសំខាន់ លើការបង្កើតឲ្យមាន ស្ថាប័ន គោលនយោបាយ និងក្របខ័ណ្ឌការងារសំខាន់ៗ និងការកសាងសមត្ថភាព។

CAMBODIA REDD+ PROGRAMME

Annex 5

## ៣ – វឌ្ឍនភាព REDD+ នៅកម្ពុជានាពេលបច្ចុប្បន្ន

- បានបង្កើតក្រុមការងារ REDD+កម្ពុជា ជាផ្លូវការនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣។
- លេខាធិការដ្ឋានក្រុមការងារ REDD+កម្ពុជា កំពុងបំពេញមុខងារ និង មានការិយាល័យនៅរដ្ឋបាលព្រៃឈើ។
- បានបង្កើតគេហទំព័រ REDD+កម្ពុជា និងឯកសារព័ត៌មានផ្សេងៗ។
- បានធ្វើសេចក្តីព្រាង យុទ្ធសាស្រ្តទំនាក់ទំនងរេដ (Draft REDD+ Communication Strategy )។

CAMBODIA REDD+ PROGRAMME



## ៥ – វឌ្ឍនភាព REDD+ នៅកម្ពុជានាពេលបច្ចុប្បន្ន(ត)

- បង្កើតក្រុមប្រឹក្សាយោបល់សម្រាប់កម្មវិធី REDD+កម្ពុជា ជាផ្លូវការ នៅថ្ងៃទី២៩ – ៣០ ខែសីហា ឆ្នាំ២០១៣ ។
- បានរៀបចំលក្ខខ័ណ្ឌការងារ ដើម្បីបង្កើតក្រុមការងារបច្ចេកទេស REDD+កម្ពុជា ។
- បានបង្កើតឲ្យមានកិច្ចប្រជុំ ក្រុមពិនិត្យឯកសារផ្សព្វផ្សាយព័ត៌មាន REDD+កម្ពុជា ។
- បានគាំទ្រគម្រោងសាកល្បង REDD+នៅឧត្តរមានជ័យ សីម៉ា និង គូលេនព្រហ្មទេព ។

CAMBODIA REDD+ PROGRAMME



## ៥ – វឌ្ឍនភាព REDD+ នៅកម្ពុជានាពេលបច្ចុប្បន្ន(ត)

- គាំទ្រគម្រោងលើកកំពស់ការយល់ដឹង និងការគាំទ្រពីសហគមន៍ ក្នុងការអភិវឌ្ឍREDD+ ខេត្តសៀមរាប អនុវត្តដោយរដ្ឋបាលព្រៃឈើ។
- គាំទ្រគម្រោងអភិរក្ស និងដាំដុះ ព្រៃលិចទឹក និងព្រៃកោងកាងឡើងវិញដើម្បី ជួយបង្កើនកាបូនស្តុក និងបន្ថយការបំភាយកាបូនអនុវត្តដោយរដ្ឋបាលជលផល។
- គាំទ្រគម្រោងការរៀបចំផែនការយុទ្ធសាស្រ្តគ្រប់គ្រងតំបន់ការពារ អភិរក្សធម្មជាតិ អនុវត្តដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ អភិរក្សធម្មជាតិ។

CAMBODIA REDD+ PROGRAMME



## សូមអរគុណ

CAMBODIA REDD+ PROGRAMME



Annex 5

CAMBODIA REDD+

**កិច្ចប្រជុំលើកទី១ក្រុមការងារ REDD+ កម្ពុជា**

ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៣

សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

## ក្រុមការងារបច្ចេកទេសរេដ+កម្ពុជា

បង្ហាញដោយ : លោក លន់ គឹមហ៊ី

អ្នកសម្របសម្រួលកម្មវិធី លេខាធិការដ្ឋានREDD+កម្ពុជា

E-mail: kimhy.lun@undp.org

## មូលហេតុ

- ក្រុមការងារបច្ចេកទេស នឹងបង្កើតសំណូមពរសំណើពាក់ព័ន្ធនិងឯកសារបច្ចេកទេសជាក់លាក់។

CAMBODIA REDD+ PROGRAMME

## ប្រតិបត្តិការ

- ក្រុមការងារបច្ចេកទេសនឹងជួបប្រជុំប្រចាំខែ ដោយមានជំនួយពីលេខាធិការដ្ឋាន
- ក្រុមការងារបច្ចេកទេស នឹងជ្រើសរើសប្រធានក្រុម ម្នាក់ពីសមាជិកក្រុម
- ក្រុមការងារបច្ចេកទេស នឹងរាយការណ៍ទៅក្រុមការងាររេដ+ កម្ពុជា តាមរយៈលេខាធិការដ្ឋាន។

CAMBODIA REDD+ PROGRAMME

## សមាជិក

- តំណាងមកពីបណ្តាក្រសួងពាក់ព័ន្ធ
- តំណាងមកពីបណ្តាទីភ្នាក់ងារអនុវត្តពាក់ព័ន្ធ
- តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ
- តំណាងមកពីលេខាធិការដ្ឋានរេដ+ កម្ពុជា ។

CAMBODIA REDD+ PROGRAMME

## ទំនាក់ទំនងការងារ

- ក្រុមការងារបច្ចេកទេស ទទួលខុសត្រូវរាយការណ៍ និងប្រឹក្សាយោបល់ ជាមួយតំណាងទីភ្នាក់ងារអនុវត្ត និងសមាជិកតាមក្រុមនីមួយៗរបស់ពួកគេ។

CAMBODIA REDD+ PROGRAMME

## ការសម្រេចចិត្ត

- ក្រុមការងារបច្ចេកទេស មិនមែនជាអ្នកធ្វើការ សម្រេចចិត្តឡើយ ប៉ុន្តែជាអ្នកបង្កើត និងផ្តល់សំណូមពរពាក់ព័ន្ធនិងឯកសារបច្ចេកទេសជូន ក្រុមការងាររេដ+កម្ពុជា។

CAMBODIA REDD+ PROGRAMME

## ការទទួលខុសត្រូវ

- ចូលរួមកិច្ចប្រជុំប្រចាំខែ
- ពិនិត្យឯកសារ ធ្វើបទបង្ហាញ និងផ្តល់យោបល់ លើឯកសារទាំងនោះ
- សហការជាមួយទីប្រឹក្សា និងមន្ត្រីលេខាធិការដ្ឋានដើម្បីបំពេញការងារ
- ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងព្រឹត្តការណ៍ផ្សេងៗ។

CAMBODIA REDD+ PROGRAMME

## ថវិកា

- ការចំណាយថវិការបស់ក្រុមការងារបច្ចេកទេសនឹងផ្តល់ដោយ កម្មវិធី UN-REDD គម្រោង FCPF និងគម្រោងដទៃទៀត ដោយយោងតាមផែនការថវិកាដែលបានអនុម័ត។

CAMBODIA REDD+ PROGRAMME

CAMBODIA REDD+

# ក្រុមការងារបច្ចេកទេស ប្រព័ន្ធធានាសុវត្ថិភាពរេដ+

បង្ហាញដោយ : លោក ឈុន ឌីលុច
មន្ត្រីបច្ចេកទេសលេខាធិការដ្ឋានREDD+កម្ពុជា
E-mail: chhundelux04@yahoo.com








## ការព្រួយបារម្ភណ៍ជាអវិជ្ជមានក្នុងការអនុវត្តយន្តការរេដ+

១. ហានិភ័យដល់សង្គម

- សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាននិង មិនអាចចូលរួមធ្វើការសម្រេចចិត្ត និងទទួលអត្ថប្រយោជន៍
- រឹតបណ្តឹង ឬហាមឃាត់ ទៅលើការប្រើប្រាស់ធនធានព្រៃឈើ
- និងអាចឈានដល់ការរុះរើទីលំនៅដោយបង្ខំ

២. ហានិភ័យដល់បរិស្ថាន

- អាចនិងមានការកែប្រែព្រៃធម្មជាតិ (e.g. ចំការឈើដាំ)
- និងអាចមានសំពាធលើតំបន់ដែលមិនមានកម្មវិធី រេដ+
- មានការផ្លាស់ប្តូរជាអវិជ្ជមាន



## គោលដៅចំបងរបស់ប្រព័ន្ធធានាសុវត្ថិភាព រេដ+

**មិនអោយមានផលប៉ះពាល់**

ប៉ះពាល់តិចបំផុត, អាចជៀសវាងបាន, លុបបំបាត់ផលប៉ះពាល់ ដល់សង្គម និងបរិស្ថាន ដែលបណ្តាលមកពីការអនុវត្តយន្តការរេដ+

**អាចផ្តល់ផលជាវិជ្ជមាន**

ផ្តល់ជាសហប្រយោជន៍(ប្រយោជន៍បន្ថែមដូចជា៖ ធ្វើឲ្យប្រសើរ ឡើងនូវ កម្មសិទ្ធិលើព្រៃឈើ, ធ្វើឲ្យប្រសើរ ឡើងនូវជីវចំរុះ..។



**សារៈប្រយោជន៍បន្ថែមទៀត**

អាចបង្កើនតំលៃនៃឥណទានកាបូន



## គោលបំណងក្រុមការងារបច្ចេកទេស ប្រព័ន្ធធានាសុវត្ថិភាព

គឺគាំទ្រការសិក្សា និងបង្កើតវិធីសាស្រ្ត សម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដ+ដោយ រួមបញ្ចូល ការប្រឹក្សាយោបល់ជាមួយអ្នក ពាក់ព័ន្ធ និងការចូលរួម ទៅក្នុងកម្មវិធី រេដ+ កម្ពុជា ។



Annex 5

## សេចក្តីសំរេចចិត្ត កិច្ចប្រជុំភាគី ទី១៦ និង ទី១៧ ក្រោមអនុសញ្ញា ក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ( UNFCCC)

**សន្ទស្សន៍ សង្គម**

- គោរពដល់ចំណេះដឹង និងសិទ្ធិរបស់ជនជាតិដើមភាគតិច និងសមាជិកសហគមន៍មូលដ្ឋាន
- បង្កើន នូវអត្ថប្រយោជន៍សង្គម

**សន្ទស្សន៍ បរិស្ថាន**

- មិនអោយមានការកែរប្រែព្រៃធម្មជាតិ
- កាត់បន្ថយ ហានិភ័យ នៃការបរិស្ថាន នៅកន្លែងផ្សេងទៀត
- អភិរក្សព្រៃធម្មជាតិ និងជីវចំរុះ
- បង្កើនអត្ថប្រយោជន៍ដល់បរិស្ថាន *(ឧ. សាវាកម្មបរិស្ថាន..)*

CAMBODIA REDD+ PROGRAMME

---

CAMBODIA REDD+

## ក្រុមការងារបច្ចេកទេស ប្រព័ន្ធចែករំលែកផលប្រយោជន៍រេដ+

បង្ហាញដោយ : លោក ឡុង រតនៈកុមារ
អនុប្រធាននាយកដ្ឋានអភិវឌ្ឍព្រៃឈើ និងសហគមន៍ព្រៃឈើ
E-mail: dfc.koma@gmail.com

---

## គោលបំណង (Objectives)

- ធានាថាមេរៀន និងបទពិសោធន៍ស្តីពីប្រព័ន្ធចែករំលែកផលប្រយោជន៍នាពេលបច្ចុប្បន្ននិងកន្លងមកនៅកម្ពុជាត្រូវបាnសិក្សាសម្រាប់សេចក្តីត្រូវការក្នុងបរិបទរេដ+ និងមេរៀនជាបTពិសោធន៍ដែលទទួលបានពីបណ្តាប្រទេសនានាត្រូវបានរួមបញ្ចូល ដើម្បីផ្តល់ជាអនុសាសន៍ដល់ការរៀបចំប្រព័ន្ធចែករំលែកផលប្រយោជន៍សម្រាប់រេដ+នៅកម្ពុជា។
- to ensure that lessons and experiences from current or previous benefit sharing systems in Cambodia are assessed in the context of REDD+ requirements; and that lessons from similar analyses in other countries are integrated to develop recommendations for a REDD+ benefit sharing system in Cambodia.

CAMBODIA REDD+ PROGRAMME

---

## ហេតុអ្វីត្រូវការបែងចែកផលប្រយោជន៍ (Why benefit-sharing?)

- ដើម្បីគាំទ្រដល់សកម្មភាពដែលឈានទៅទទួលលទ្ធផលវិជ្ជមាន
- ផលប្រយោជន៍ត្រូវបានគេយល់ទាំងផលប្រយោជន៍ជាថវិកា និង មិនមែនថវិកា រួមមានធ្វើឲ្យប្រសើរឡើងនូវសិទ្ធិ និងការប្រើប្រាស់ធនធន។

- To incentivize actions which leads to a positive result.
- Benefits can be understood as both monetary and non-monetary benefits including improved rights and continued access to resources.

CAMBODIA REDD+ PROGRAMME

Annex 5

## បញ្ហាការបែងចែកផលប្រយោជន៍ (Benefit-sharing issues)

- អ្នកពាក់ព័ន្ធចាប់អារម្មណ៍លើការបែងចែកផលប្រយោជន៍និងពេលខ្លះការរំពឹងទុកមិនប្រាកដប្រជាចំពោះការបែងចែកផលប្រយោជន៍
- ការបែងចែកផលប្រយោជន៍ហិរញ្ញប្រទានគឺអាស្រ័យលើថាតើមានផលប្រយោជន៍ដើម្បីបែងចែកដែរឬទេ(លទ្ធផលរ៉េដបូក)

- All stakeholders are interested in benefit- sharing and sometimes with unrealistic expectations regarding benefit sharing.
- Financial benefit sharing depends on whether there are benefits to share (REDD+ results).

CAMBODIA REDD+ PROGRAMME

REDD+ CAMBODIA

CAMBODIA REDD+

## ក្រុមការងារបច្ចេកទេស សាកល្បងគម្រោងគំរូរេដ+

បង្ហាញដោយ : លោក ឡុង រតនៈកុមារ
អនុប្រធាននាយកដ្ឋានអភិវឌ្ឍព្រៃឈើ និងសហគមន៍ព្រៃឈើ
E-mail: dfc.koma@gmail.com

## គោលបំណង (Objectives)

- គឺជានាថាមេរៀន និងបទពិសោធន៍ ដែលបានមកពីការអនុវត្តគម្រោងគំរូ ត្រូវបានកត់ត្រា និងវិភាគ ដើម្បីគាំទ្រដល់ការបង្កើតវិធីសាស្ត្រ សម្រាប់អនុវត្តនៅថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃកម្មវិធី រេដ+ថ្នាក់ជាតិ។ ក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគំរូ ត្រូវគាំទ្រដល់ការបង្កើតគោលការណ៍ណែនាំសម្រាប់វិធីសាស្ត្រអនុវត្តនៅថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃវិធីសាស្ត្រសំបុកសត្វ នៅក្នុងក្របខ័ណ្ឌការងារថ្នាក់ជាតិ ដោយរួមបញ្ចូលទាំងអនុសាសន៍សម្រាប់អនុវត្តគម្រោងគំរូផងដែរ ។

CAMBODIA REDD+ PROGRAMME

## ក្រុមការងារបច្ចេកទេសសាកល្បងគម្រោងគំរូរេដ+

- ក្រុមការងារបច្ចេកទេស ត្រូវគាំទ្រដល់ការបង្កើតគោលការណ៍ណែនាំ សម្រាប់វិធីសាស្ត្រអនុវត្តនៅថ្នាក់ក្រោមជាតិ ដែលជាផ្នែកនៃវិធីសាស្ត្រសំបុកសត្វនៅក្នុងក្របខ័ណ្ឌការងារថ្នាក់ជាតិ ដោយរួមបញ្ចូលតំបន់សាកល្បងផងដែរ។

- The team should support the development of guidelines for possible REDD+ sub-national approaches as part of a nested approach in a national framework including recommendations for demonstration sites.

CAMBODIA REDD+ PROGRAMME

Annex 5

## ហេតុអ្វីបង្កើតគោលការណ៍ណែនាំគម្រោងគំរូរេដ+

- គោលបំណងរបស់ UNFCCC រេដ គឺត្រូវអនុវត្តនៅកំរិតជាតិ ស្របពេលជាមួយគ្នានេះ ទីផ្សារកាបូនស្ម័គ្រចិត្ត បាននិងកំពុងអនុវត្ត និងជាជំរើសសម្រាប់ការអនុវត្តនៅថ្នាក់គម្រោងពេលបច្ចុប្បន្ន។
  - ជំហានទី១៖ការអនុវត្តនៅកំរិតគម្រោង
  - ជំហានទី២៖ការអនុវត្តនៅកំរិតថ្នាក់ក្រោមជាតិ
  - ជំហានទី៣៖ការអនុវត្តនៅកំរិតថ្នាក់ជាតិ
- ត្រូវធានាថាវិធីសាស្រ្តអនុវត្តនឹងបំពេញមុខងារស្របគ្នា និង ផ្តល់យោបល់ថាតើរេដត្រូវមានវឌ្ឍនភាពដោយរបៀបណា

CAMBODIA REDD+ PROGRAMME

---

CAMBODIA REDD+

## ក្រុមការងារបច្ចេកទេស

## ក្រុមការងារបច្ចេកទេស MRV/REL

បង្ហាញដោយ : លោកស្រី សារ សុភីរ៉ា
មន្រ្តីបច្ចេកទេស នាយកដ្ឋានអភិវឌ្ឍព្រៃឈើ និងសហគមន៍ព្រៃឈើ
E-mail: sophyra.sar@gmail.com

---

## គោលបំណងក្រុមការងារបច្ចេកទេស MRV/REL
### (MRV/REL Technical Team)

គឺធានាថាសមត្ថភាព បច្ចេកទេសពាក់ព័ន្ធនឹង រេដ+ បានផ្តល់ជូនស្ថាប័នក្រុមការងាររេដ+ លេខាធិការដ្ឋាន រេដ+ និងសមាសភាគសំខាន់ៗរបស់រេដ+ ដើម្បីបំពេញមុខងារ ប្រកបដោយតម្លាភាព សង្គហាតិភាព ត្រួតពិនិត្យដោយគ្មានលំអៀង និងមានប្រព័ន្ធ ត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ។

CAMBODIA REDD+ PROGRAMME

---

## ហេតុអ្វីត្រូវវាស់វែង រាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន ( Why MRV/REL ? )

- វាស់វែង រាយការណ៍ ផ្ទៀងផ្ទាត់(MRV) ជាតម្រូវការចាំបាច់ ដើម្បី ប៉ាន់ប្រមាណតំបន់ព្រៃឈើ និងស្តុកកាបូន សម្រាប់ រាយការណ៍ និងផ្ទៀងផ្ទាត់ ។
- កំរិតយោងនៃការបញ្ចេញឧស្ម័ន(REL) ជាតម្រូវការចាំបាច់ ដើម្បី គណនាលទ្ធផល នៃការស្រូប ឬ ការបញ្ចេញឧស្ម័ន ។

CAMBODIA REDD+ PROGRAMME

## មុខងារត្រួតពិនិត្យសកម្មភាពរេដ+

### មុខងារត្រួតពិនិត្យ

- ប្រព័ន្ធរូបភាពផ្កាយរណប
- គេហទំព័រ
- ការត្រួតពិនិត្យសហគមន៍
- ប្រព័ន្ធត្រួតពិនិត្យផ្សេងទៀតទាក់ទងទៅនិងព្រៃឈើ

### មុខងារវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់

- ប្រព័ន្ធត្រួតពិនិត្យចំណាត់ថ្នាក់ដីដោយរូបភាពផ្កាយរណប
- សារពើភ័ណ្ឌព្រៃឈើថ្នាក់ជាតិ
- សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់

45

## ធាតុនៃ MRV សម្រាប់រេដ+

**វាស់វែង**

ទិន្នន័យសកម្ម: ប្រព័ន្ធត្រួតពិនិត្យចំណាត់ដី × កត្តាបំភាយ: សារពើភ័ណ្ឌព្រៃឈើថ្នាក់ជាតិ



**រាយការណ៍**

= សារពើភ័ណ្ឌ GHG សម្រាប់រេដ+

- LULUCF Inventory → Inventory Complication QA/QC → Emission Inventory Database → UNFCCC

**ផ្ទៀងផ្ទាត់**

UNFCCC

CAMBODIA REDD+ PROGRAMME

## ការទទួលខុសត្រូវ

ការទទួលខុសត្រូវជាក់លាក់របស់ក្រុមបច្ចេកទេស ត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ និងកំរិតបំភាយយោង(MRV/REL) គឺ ៖

- បង្កើតចំណាត់ថ្នាក់ព្រៃឈើជាតិ
- បង្កើតប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ ផ្ទៀងផ្ទាត់ និងកំរិតបំភាយ យោងសម្រាប់រេដ+នៅកម្ពុជា
- បង្កើតប្រព័ន្ធវាយតម្លៃគម្របព្រៃឈើជាតិ ដោយរូបភាពផ្កាយរណប (design the satellite forest monitoring system)
- បង្កើតគំរូសារពើភ័ណ្ឌព្រៃឈើជាតិ
- បង្កើតរយៈពេលយោង (reference period)
- បង្កើតកំរិតយោងថ្នាក់ជាតិ (National reference levels)

CAMBODIA REDD+ PROGRAMME

## ការទទួលខុសត្រូវ(ត)

- បង្កើតហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស ដើម្បីរៀបចំអនុវត្តប្រព័ន្ធវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ព្រៃឈើ
- កំណត់ស្ថាប័នទទួលខុសត្រូវក្នុងការត្រួតពិនិត្យ វាស់វែង  រាយការណ៍ និងផ្ទៀងផ្ទាត់ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាល មកពីការការបាត់បង់ និងរិចរឹលព្រៃឈើ
- រក្សាទិន្នន័យដើមសម្រាប់ការត្រួតពិនិត្យ វាស់វែង  រាយការណ៍ និងផ្ទៀងផ្ទាត់ ព្រៃឈើ
- សម្របសម្រួលដល់ការប្រើប្រាស់ និងចែកចាយទិន្នន័យដល់អ្នកពាក់ព័ន្ធ ត្រួតពិនិត្យ QC/QA និងផ្ទៀងផ្ទាត់។

CAMBODIA REDD+ PROGRAMME

Annex 5

## ការទទួលខុសត្រូវ( ត )

- រៀបចំការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់(GHG) ជាបណ្តោះអាសន្ន ដែលពាក់ព័ន្ធនិង ការប្រើប្រាស់ដី ការផ្លាស់ប្តូរ ការប្រើប្រាស់ដី និងព្រៃឈើ (LULUCF) ។
- បង្កើតផែនការអនុវត្តប្រចាំត្រីមាស និងប្រចាំឆ្នាំ និងកែសម្រួលផែនការសម្រាប់ការគ្រប់គ្រងទិន្នន័យ
- បំពេញកាតាព្វកិច្ចដទៃទៀតដែលពាក់ព័ន្ធនឹងការបង្កើត និងការអភិវឌ្ឍន៍ប្រព័ន្ធ ត្រួតពិនិត្យ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាល មកពីការការបាត់បង់ និងរិចរឹលព្រៃឈើ។

CAMBODIA REDD+ PROGRAMME

CAMBODIA REDD+

**កិច្ចប្រជុំលើកទី១ក្រុមការងារ REDD+ កម្ពុជា**

ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៣

សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

# យុទ្ធសាស្ត្រទំនាក់ទំនងរេដ+កម្ពុជា

## ស្ថានភាពបច្ចុប្បន្ន និងទិសដៅអនាគត

បង្ហាញដោយ : កញ្ញា ធី ហៀង
មន្ត្រីទំនាក់ទំនង លេខាធិការដ្ឋានREDD+កម្ពុជា
E-mail: heang.thy@undp.org

## ស្ថានភាពនៅប្រទេសមួយចំនួន




CAMBODIA REDD+ PROGRAMME

## ទិសដៅសម្រាប់កម្ពុជា




CAMBODIA REDD+ PROGRAMME

Annex 5

## វឌ្ឍនភាពនាពេលបច្ចុប្បន្ន

- យុទ្ធសាស្ត្រទំនាក់ទំនង UN-REDD អនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិកម្មវិធី
- ក្រុមប្រឹក្សាប្រតិបត្តិកម្មវិធីស្នើឲ្យលេខាធិការដ្ឋាន(RTS)ពិភាក្សាយោបល់ជាមួយដៃគូពាក់ព័ន្ធ ថាគួរបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់រេដ+កម្ពុជាឬទេ?
- RTS បានពិភាក្សាយោបល់ជាមួយដៃគូពាក់ព័ន្ធ និងបានចម្លើយថា គួរបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់កម្មវិធីរេដ+។
- RTS បានរៀបចំ និងដឹកនាំដំណើរការកិច្ចប្រជុំជាមួយដៃគូពាក់ព័ន្ធនិងបានកំណត់តម្រូវការឯកសារផ្សព្វផ្សាយទំនាក់ទំនង និងបានប្រមូលឯកសារផ្សព្វផ្សាយដែលមានស្រាប់ និងរៀបចំផែនការដើម្បីរៀបចំបោះពុម្ព និងផ្សព្វផ្សាយទៅលើផ្នែកដែលខ្វះខាត។
- RTS ក៏បានបង្កើតនូវព្រឹត្តិបត្រព័ត៌មានលេខទី១ ខិត្តប័ណ្ណអំពីរេដ+កម្ពុជា និងវីដេអូឃ្លីបអំពីរេដ+ សម្រាប់កម្មវិធីរេដ+កម្ពុជា។

CAMBODIA REDD+ PROGRAMME

## សំណើសុំការសម្រេចចិត្តពីក្រុមការងាររេដ+

**លេខាធិការដ្ឋានសុំសំណូមពរ៖**

ក្រុមការងាររេដ+កម្ពុជា បង្គាប់ និងអនុញ្ញាតិយល់ព្រមឲ្យលេខាធិការដ្ឋាន ក្នុងការដឹកនាំក្នុងការបង្កើតឲ្យមានយុទ្ធសាស្ត្រទំនាក់ទំនងរេដ+កម្ពុជា និងសូមឲ្យប្រើប្រាស់ថវិកាUN-REDD ក្នុងការគាំទ្រដំណើការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងនេះ នៅដើមត្រីមាសទី៤ ឆ្នាំ២០១៣នេះ។

CAMBODIA REDD+ PROGRAMME

# សូមអរគុណ

CAMBODIA REDD+ PROGRAMME

## ទស្សនកិច្ចសិក្សា នៅប្រទេសវៀតណាម សម្រាប់ ប្រតិភូ "ក្រុមការងាររេដបូកកម្ពុជា"

០៦ ដល់ ១១ តុលា ២០១៣

Annex 5

## ទស្សនកិច្ចសិក្សា

- ស្វែងយល់ពីបទពិសោធន៍នៃប្រទេសវៀតណាម លើដំណើការត្រៀមលក្ខណៈសម្រាប់រេដ
- រយៈពេល ៥ថ្ងៃ (៦ ដល់ ១១ ខែតុលា ២០១៣)
- រៀបចំដោយ រដ្ឋបាលព្រៃឈើនៃប្រទេសវៀតណាម (VNFOREST) តាមរយៈការិយាល័យ REDD+ សហការជាមួយ RECOFTC វៀតណាម

CAMBODIA REDD+ PROGRAMME

## កម្មវិធីទស្សកិច្ចសិក្សា

- ០៦ តុលា ២០១៣៖ ការធ្វើដំណើរពីភ្នំពេញ ទៅ ហាណូយ របស់គណៈប្រតិភូ
- ០៧ តុលា ២០១៣៖
  - កិច្ចស្វាគមន៍របស់ VNFOREST និងRECOFTC
  - ស្វែងយល់ពីដំណើររេដ+ នៅវៀតណាម
  - ពិភាក្សាតុមូលលើប្រធានបទដែលពាក់ព័ន្ធនឹងដំណើរការរេដ+




CAMBODIA REDD+ PROGRAMME

## កម្មវិធីទស្សកិច្ចសិក្សា

- ០៨ តុលា ២០១៣៖
  - គណៈប្រតិភូធ្វើដំណើរទៅកាន់ខេត្ត Lam Dong
  - កិច្ចស្វាគមន៍របស់គណៈកម្មធិការប្រជាជនខេត្ត Lam Dong
  - ជួបពិភាក្សាជាមួយ ក្រុមការងាររេដ+ នៃខេត្ត Lam Dong
  - ជួបពិភាក្សាជាមួយ ក្រុមការងារគម្រោងរេដ+ នៃអង្គការ SNV




CAMBODIA REDD+ PROGRAMME

## កម្មវិធីទស្សកិច្ចសិក្សា

- ០៩ តុលា ២០១៣៖
  - ទស្សនកិច្ចទៅកាន់តំបន់គោលដៅ នៃ UN-REDD ដំណាក់កាលទី១ (ស្រុក Lam Ha ឬ ស្រុក Di Linh)
  - ធ្វើដំណើរទៅកាន់ស្រុក Bao Loc
- ១០ តុលា ២០១៣៖
  - ទស្សនកិច្ចទៅកាន់តំបន់គោលដៅគម្រោងនៃអង្គការ SNV នៅស្រុក Bao Loc
  - ឆ្លុះបញ្ចាំងពីលទ្ធផលនៃទស្សនកិច្ចសិក្សា
- ១១ តុលា ២០១៣៖ ដំណើរត្រឡប់របស់គណៈប្រតិភូ

CAMBODIA REDD+ PROGRAMME

Annex 5

# សូមអរគុណ

CAMBODIA REDD+ PROGRAMME

